00802978 E189

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ: | ក្រុមមេធាវីការពារក្តីលោក នួន ជា |
| ដាក់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម: | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ: | ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Apr-2012, 14:14
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ**/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំឲ្យមានវិធានការជាបន្ទាន់ដោយអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៣៥**

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
Jacqueline Greene

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

## I. សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") មេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្ដី") តទៅនេះសូមដាក់សំណើនេះសុំឱ្យមានវិធានការជាបន្ទាន់ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងការឆ្លើយតបទៅនឹងការលាឈប់ពីតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet ។ សម្រាប់មូលហេតុនានាដែលបញ្ជាក់ដូចខាងក្រោម មេធាវីការពារក្ដីយល់ឃើញថាវិធានការបែបនេះ គឺយឺតពេលយូរណាស់មកហើយ។ ផ្អែកតាមបញ្ហាដ៏សំខាន់ដែលបានលើកឡើងនៅក្នុងសំណើនេះនិងផលប្រយោជន៍ទូទៅនៅក្នុងដំណើរការជំនុំជម្រះដោយតម្លាភាព សំណើនេះត្រូវតែបានចាត់ទុកជាសាធារណៈ។ នៅគ្រប់កាលៈទេសៈទាំងអស់ក្រុមមេធាវីការពារក្ដីចាត់ទុកសំណើនេះជាសាធារណៈ ។

## II. អង្គហេតុដែលពាក់ព័ន្ធ

### ក. កិច្ចប្រឹងប្រែងលើកមុនដោយមេធាវីការពារក្ដី

២. ការប្រឹងប្រែងលើកមុនដោយមេធាវីការពារក្ដី ទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ និងការជ្រៀតជ្រែកខាងនយោបាយដែលមានយូរណាស់មកហើយ និងដែលកំពង់តែបន្តនៅក្នុងកិច្ចការរបស់តុលាការទាំងមូល ត្រូវបានសង្ខេបចូលក្នុងឯកសារបីសំខាន់ៗដែលដាក់កាលពីខែ តុលា ឆ្នាំមុន[1]។ នៅក្នុងសារណាទាំងនេះ-បណ្ដឹងសារទុក្ខភ្លាមៗ, បណ្ដឹងព្រហ្មទណ្ឌ និង សំណើសុំផ្អាកការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដី- មេធាវីការពារក្ដីលើកហេតុផលក្នុងចំណោមបញ្ហាដទៃទៀតថា "វាពិតជាច្បាស់មិនអាចប្រកែកបានថាមន្ត្រី/ឬភ្នាក់ងាររបស់រាជរដ្ឋាភិបាលកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាល) បានជ្រៀតជ្រែកដោយមិនត្រឹមត្រូវទាល់តែសោះក្នុងកិច្ចការរបស់តុលាការ និងកំពុងតែបន្តការជ្រៀតជ្រែកបែបនេះ

[1] ឯកសារ E-116/1/1, "បណ្ដឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេត" ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២, ERN 00746636–00746658 "បណ្ដឹងសារទុក្ខភ្លាមៗ ទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេត" ។ ឯកសារ E-131/2.1.1, បណ្ដឹងព្រហ្មទណ្ឌ" ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ERN 00749616–00749624 (បណ្ដឹងព្រហ្មទណ្ឌ) ។ ឯកសារ E-131/2, សំណើសុំផ្អាកការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដី" ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ERN 00749600–00749612 (សំណើសុំផ្អាកការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដី")។

តទៅទៀត[2]។ ជាពិសេស មេធាវីការបានលើកឡើងម្តងហើយម្តងទៀតនូវបញ្ហាដូចខាងក្រោម: (i) ព្រមជាមួយមន្ត្រីរដ្ឋាភិបាលជាក់លាក់មួយចំនួន សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង រារាំងកិច្ចប្រឹងប្រែងដោយសមាសភាគីអន្តរជាតិរបស់គាត់ដើម្បីស្តាប់ព្រះចម្លើយព្រះបិតាជាតិ នរោត្តម សីហនុ ជាសាក្សី[3] (ii) មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលប្រាំមួយរូបខកខានមិនបានចូលខ្លួនមកការិយាល័យសហចៅក្រមស៊ើបអង្កេត តាមដីកាកោះហៅដែលចេញដោយស្របច្បាប់ ហើយលោក ហ៊ុន សែន និងសមាជិកដទៃទៀតនៃរាជរដ្ឋាភិបាលកម្ពុជាបានសម្រួល និងគាំទ្រដល់ការមិនចូលខ្លួនរបស់មន្ត្រីជាន់ខ្ពស់ទាំងនោះ[4] និង(iii) លោកនាយករដ្ឋមន្ត្រីដែលបានត្រូវបានគាំទ្រ និងជម្រុញដោយសមាជិកជាច្រើននៃរាជរដ្ឋាភិបាលកម្ពុជា គឺជាកិច្ចប្រឹងប្រែងធ្វើឲ្យបរាជ័យសំណុំរឿង ០០៣ និង០០៤[5] ។

៣. ទាក់ទងនឹងបញ្ហាចុងក្រោយ មេធាវីការពារក្តីបានបញ្ជាក់ទំនាក់ទំនងយ៉ាងច្បាស់មួយទៅនឹងសំណុំរឿងបច្ចុប្បន្ននេះ "ការជ្រៀតជ្រែកដោយរាជរដ្ឋាភិបាលកម្ពុជាបានកើតមានយ៉ាងច្បាស់ដែលបង្ហាញយ៉ាងជាក់ច្បាស់ពីភាពអាចជឿជាក់បាននៃការជ្រៀតជ្រែកនៅខាងក្រោយឆាក។ ប្រហែលជាចំនុចមួយបានបាត់នៅក្នុងការរំជើបរំជួលនាពេលថ្មីៗនេះទាក់ទងនឹងសំណុំរឿង ០០៣ និង០០៤ គឺជាអនុសាសន៍ដ៏សំខាន់: ដរាបណារដ្ឋាភិបាលបដិសេធមិនឲ្យមានការចោទប្រកាន់បន្ថែម នោះហើយជាគាំទ្រដល់ចំនុចចុងក្រោយ។ នៅក្នុងបរិបទនយោបាយកម្ពុជាបច្ចុប្បន្ននេះ ការគាំទ្របែបនេះ គឺតែងតែមានលក្ខខណ្ឌភ្ជាប់ជាមួយ។ ដើម្បីឲ្យប្រាកដ រាជរដ្ឋាភិបាលកម្ពុជាមានទស្សនស៊ីចង្វាក់គ្នាថាតើសំណុំរឿង ០០២ ត្រូវដោះស្រាយជាចុងក្រោយដោយរបៀបណា ។ បញ្ហានៅតែមានថា តើចៅក្រមកម្ពុជានៅសាលាក្តីនេះ គោរពតាមចំណាររបស់រដ្ឋាភិបាលក្នុងកម្រិតណា[6] ។ តាមពិតលោកនាយករដ្ឋមន្ត្រីបាននិយាយជាសាធារណៈថា លោក នួន ជា គឺជាអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍[7] ។ ជាការមិនអាចចៀសផុតទេដែលថា ចៅក្រមកម្ពុជារបស់តុលាការនេះនឹង

---

[2] បណ្តឹងសារទុក្ខភ្លាមៗទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតនៅកថាខណ្ឌទី២ ។

[3] បណ្តឹងសារទុក្ខភ្លាមៗទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតនៅកថាខណ្ឌទី៣(ខ) និង សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៅកថាខណ្ឌទី២(ខ) ។

[4] បណ្តឹងសារទុក្ខភ្លាមៗទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតនៅកថាខណ្ឌទី៣(គ) និង សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៅកថាខណ្ឌទី២(ខ)-(ឃ) ។

[5] បណ្តឹងសារទុក្ខភ្លាមៗទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតនៅកថាខណ្ឌទី៣(ឃ)និង សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៅកថាខណ្ឌទី២(ង)-(ច) ។

[6] បណ្តឹងសារទុក្ខភ្លាមៗទាក់ទងនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេតនៅកថាខណ្ឌទី៣៧ (ការសំអាងផ្នែកក្នុងត្រូវបានលុបចោល) ។

[7] សូមមើលកថាខណ្ឌ ៥ ខាងក្រោម។

ពិតជាចោទប្រកាន់លោក នួន ជា ដូច្នេះដែរ ដោយមិនគិតដល់កំណត់ហេតុអង្គហេតុបង្កើតឡើងដោយតុលាការនេះ។

៤. បន្ថែមពីលើឯកសារបីដែលយោងពីខាងលើ (ក្នុងកថាខណ្ឌ២) មេធាវីការពារក្ដីបានអំពាវនាវជាសាធារណៈឱ្យចៅក្រម យូ ប៊ុនឡេង លាឈប់ពីមុខតំណែង[8] ។ ជាការប្រតិកម្មតបទៅនឹងការបង្ហើបឱ្យដឹងថាសហចៅក្រមស៊ើបអង្កេតជាតិបាន "ប្រព្រឹត្តភាពមិនប្រក្រតីធ្ងន់ធ្ងរខាងនីតិវិធី រួមទាំងចុះកាលបរិច្ឆេទត្រឡប់ក្រោយលើឯកសារ ការលួចកែលើឯកសារនានា និងការខកខានមិនបានបញ្ជូនការជូនដំណឹងទៅមេធាវី[9] នៅក្នុងសំណុំរឿង០០៣ ទើបមេធាវីការពារក្ដីឈានទៅដល់ការធ្វើសេចក្ដីសន្និដ្ឋានថាចៅក្រម យូ ប៊ុនឡេង [...] បានប្រព្រឹត្តនូវទង្វើដែលអាចហៅថាជាបទល្មើស[10]។ លើសពីនេះទៅទៀត ដោយសារតួនាទីជាមូលដ្ឋានរបស់គាត់នៅក្នុងការដឹកនាំការស៊ើបសួរ និងពង្រាងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ហេតុដូច្នេះការបង្ហើបឱ្យដឹងថ្មីៗនេះ [...] នាំឱ្យមានមន្ទិលសង្ស័យថែមទៀតអំពីសុចរិតភាពនៃសំណុំរឿង និងដីកាដំណោះស្រាយ[11]។ មេធាវីការពារក្ដីបានបញ្ជូនសំណៅនៃលិខិតរបស់ខ្លួនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលចៅក្រម យូ ប៊ុនឡេង ជាសមាជិក "ព្រមជាមួយសំណើសុំឱ្យមានការស៊ើបអង្កេតខាងវិន័យទៅក្នុងការប្រព្រឹត្តរបស់គាត់[12]។ ដូចដែលបានបញ្ជាក់រួចមកហើយ មេធាវីការពារក្ដីយល់ឃើញយ៉ាងមុតមាំថាការបន្តវត្តមានរបស់[គាត់] នៅ អវតក នឹងធ្វើឱ្យកិត្យានុភាពរបស់ស្ថាប័នមួយនេះកាន់តែចុះថយថែមទៀត[13]។

៥. តាំងតែពីការចាប់ផ្ដើមសវនាការលើអង្គសេចក្ដីនៅខែ វិច្ឆិកា ឆ្នាំ ២០១១ មក ក្រុមមេធាវីការពារក្ដីបានបញ្ជាក់ម្ដងហើយម្ដងទៀតពីជំហររបស់ខ្លួនទាក់ទងទៅនឹងការជ្រៀតជ្រែកនយោបាយ។ ក្នុងន័យនេះ ក្រុមមេធាវីការពារក្ដីបានស្នើសុំឱ្យមាននូវដំណោះស្រាយជាបន្ទាន់ពីអង្គជំនុំជម្រះសាលាដំបូង ដើម្បីជាការឆ្លើយតបទៅនឹងការលើកឡើងជាសាធារណៈរបស់លោក ហ៊ុន សែន អំពី នួន

---

[8] សូមមើលលិខិតពីក្រុមមេធាវីការពារ នួន ជា ទៅចៅក្រម យូ ប៊ុនឡេង កម្មវត្ថុ "សំណើសុំបញ្ជីភស្តុតាងដែលជិតដាមដោយនៅក្នុងសំណុំរឿង ០០២ និងសុំឱ្យមានលាឈប់ពីតំណែង" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ (លិខិតទៅចៅក្រម យូ ប៊ុនឡេង) ។

[9] Julia Wallace, *Cambodia Daily*, 'KRT Judges List Failings of Blunk, Bunleng', ចុះផ្សាយថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០១១ ។

[10] លិខិតទៅចៅក្រម យូ ប៊ុនឡេង ទំព័រ១ ។

[11] ដូចខាងលើ ។

[12] ដូចខាងលើ ។

[13] ដូចខាងលើ ។

ជា ថាជាឃាតករ និងជនដែលដល់នៃអំពើប្រល័យពូជសាសន៍[14]។ តែមកទល់ពេលនេះអង្គជំនុំជម្រះនេះបានសម្ដែងការព្រួយបារម្ភតិចតួច និងពុំមានបំណងដោះស្រាយបញ្ហានេះទាល់តែសោះ ។

### ខ. កិច្ចប្រឹងប្រែងរបស់ចៅក្រម Kasper-Ansermet គឺការលាឈប់ និងការលាតត្រដាង

៦. បន្ទាប់ពីការចាកចេញដ៏អាម៉ាសរបស់ចៅក្រម Siegfried Blunk ចៅក្រម Kasper-Ansermet បំពេញតួនាទីជាសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិកាលពីចុងឆ្នាំមុននេះ ។ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ គាត់ព្យាយាមសើរើឡើងវិញនូវការស៊ើបសួរដែលជិតនឹងស្លាប់ទៅហើយ និងត្រូវបានធ្វើឱ្យជាប់គាំងដោយចៅក្រម Seigfried Blunk និងចៅក្រម យូ ប៊ុនឡេង[15]។ ប៉ុន្តែ តាមរយៈការបកស្រាយប្រកបដោយមន្ទិលសង្ស័យលើលិខិតុបករណ៍ច្បាប់ អវតក រាជរដ្ឋាភិបាលកម្ពុជាដែលបានប្រើប្រាស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាឧបករណ៍របស់ខ្លួន[16] បានបដិសេធមិនទទួលស្គាល់ចៅក្រម Kasper-Ansermet ជាមន្ត្រីតុលាការពេញសិទ្ធិនៅតុលាការនេះទេ។ ទោះជាយ៉ាងនេះក្ដី អង្គការសហប្រជាជាតិ(ដែលមានលោក David Scheffer ជាទីប្រឹក្សាពិសេសរបស់លោកអគ្គលេធិការអង្គការសហប្រជាជាតិ) ប្រកាសការគាំទ្រយ៉ាងពេញទំហឹងដល់ចៅក្រម Kasper-Ansermet និងបានរំលឹកដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យគោរពកាតព្វកិច្ចតាមសន្ធិសញ្ញារបស់ខ្លួន។ រដ្ឋាភិបាលដែលតែងតែបដិសេធមិនយល់ព្រមចំពោះអ្វីដែលខ្លួនចាត់ទុកដោយមិនស្មោះត្រង់ថា ជាការជ្រៀតជ្រែកពីសំណាក់អន្តរជាតិ ប្រកាន់យកជំហរនេះយ៉ាងរឹងមាំ ហេតុដូច្នេះ ល្បែងផ្លូវច្បាប់ដ៏ចម្លែកត្រូវបានលាតត្រដាងនៅ អវតក ជាមួយចៅក្រម Kasper-Ansermet បំពេញតួនាទីសុចរិតទៀងត្រង់ផ្អែកតាមសិទ្ធិអំណាចរបស់គាត់[17] ខណៈដែលបុគ្គលិកកម្ពុជានៅ កសចស ក្រោមការបញ្ជានិងត្រួតត្រាពីចៅក្រម យូ ប៊ុនឡេង បានរារាំងសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ក្រោមរូបភាពទាំងអស់ ។

៧. នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២ ចៅក្រម Kasper-Ansermet បានប្រកាសជាសាធារណៈពីការដាក់ការខ្វែងយោបល់គ្នាជាផ្លូវការរវាងគាត់ និងចៅក្រម យូ ប៊ុនឡេង ព្រមទាំងការខកខានរបស់

---

[14] សូមមើលឯកសារ E-176 "សំណើនេះសុំចំណាត់ការសង្គ្រប្រឆាំងនឹងនាយ រដ្ឋមន្ត្រី ហ៊ុន សែន ដោយអនុលោមតាម វិធាន ៣៥" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00782947–00782959 (សំណើ ហ៊ុន សែន) នៅកថាខណ្ឌ ២។

[15] សូមមើលសំណុំរឿង ០០៣ និង០០៤, ឯកសារ D-28 "ដីកាបង្គាប់ឱ្យស៊ើបសួរឡើងវិញ" ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ។

[16] ដូចដែលបានកត់សម្គាល់រួចមកហើយ ចៅក្រម យូ ប៊ុនឡេង គឺជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

[17] កត់សម្គាល់៖ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ចៅក្រម Kasper-Ansermet ប្រកាស "សិទ្ធិអំណាចពេញលេញផ្លូវច្បាប់របស់គាត់ ដើម្បីបំពេញមុខងាររបស់គាត់ជាសហចៅក្រមស៊ើបអង្កេតប្រចាំការ បើទោះបីមានជំទាស់របស់ឧត្តមប្រឹក្សានៃអង្គចៅក្រមទៅនឹងការចាត់តាំងគាត់ ។

អង្គបុរេជំនុំជម្រះក្នុងការទទួលស្គាល់សុពលភាពនៃការខ្វែងយោបល់គ្នា ដោយផ្អែកលើការមិនគាំទ្រដល់ចៅក្រម Kasper-Ansermet ។ សូមកត់សម្គាល់ថា "ស្ថានភាពនេះបង្កើតឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរអំពីកង្វះភាពឥតលម្អៀងរបស់ចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ, សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិដាក់ "ពាក្យសុំជិតចិត្តប្រឆាំងគាត់" [...] នៅអង្គបុរេជំនុំជម្រះដោយស្នើសុំឱ្យចៅក្រម ប្រាក់ គឹមសាន លាឈប់ពីតំណែងដោយស្ម័គ្រចិត្តពីដំណើរការនីតិវិធីទាក់ទងនឹង [សំណុំរឿង ០០៣ និង ០០៤][18]។ សេចក្ដីប្រកាសព័ត៌មានដែលចេញដោយចៅក្រមអន្តរជាតិនៅអង្គបុរេជំនុំជម្រះបង្ហាញថា "បញ្ហា [ត្រូវបាន] បង្វិលដោយគ្មានការពិភាក្សា ឬពិគ្រោះយោបល់ជាមួយចៅក្រមនៃ [អង្គបុរេជំនុំជម្រះ] ទៅ [ចៅក្រម Kasper-Ansermet] ដោយប្រធាន[អង្គបុរេជំនុំជម្រះ][19]។

៨. ដោយសម្លឹងមើលពីភាពធ្ងន់ធ្ងរនៃស្ថានការណ៍នៅក្នុង កសចស ចៅក្រម Kasper-Ansermet ថ្លែងយ៉ាងរាក់ទាក់ទៅកាន់សារព័ត៌មាននៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ "បញ្ហានេះមិនអាចឱ្យតុលាការធ្វើការដោយងាយស្រួលទេ [...] ។ *ស្ថានការណ៍នេះនឹងឱ្យជាលទ្ធផល រួមទាំងការជំនុំជម្រះលើអតីតមេដឹកនាំខ្មែរក្រហម*[20]។ បីថ្ងៃក្រោយមក សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិប្រកាសថា "សិទ្ធិអំណាចរបស់គាត់ដើម្បីស៊ើបសួរសំណុំរឿង ០០៣ និង ០០៤ ត្រូវបានជំទាស់ជារហូតដោយ [ចៅក្រម យូ ប៊ុនឡេង] ហើយថាការប្រឆាំងជំទាស់យ៉ាងសកម្មបែបនេះ[...] នាំឱ្យទៅដល់ស្ថានការណ៍នៃភាពមិនអាចដំណើរការបាននៅក្នុង អវតក[21]។ ចៅក្រម Kasper-Ansermet បានកត់សម្គាល់បន្ថែមទៀតថា "ការរៀបរាប់អំពីស្ថានការណ៍[នឹង]ត្រូវផ្សព្វផ្សាយទាន់ពេលវេលា និងថា"ការស៊ើបអង្កេតផ្ទៃក្នុង [បាន] ចាប់ផ្ដើមតាមវិធាន ៣៥ ចំពោះ"ការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ"[22]។ ការពិពណ៌នាអំពី"ឧសានវាទ"ពីសហការីកម្ពុជារបស់គាត់ "ដែលបានទាមទារឱ្យគាត់បញ្ឈប់ជាបន្ទាន់ "សកម្មភាពខុសច្បាប់របស់គាត់" ចៅក្រម Kasper-Ansermet បានលើកឡើងថា "កាលៈទេសៈបច្ចុប្បន្នមិនអនុញ្ញាតឱ្យគាត់បំពេញតួនាទី

---

[18] សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ។

[19] សេចក្ដីថ្លែងការណ៍ដោយចៅក្រម Judges Downing , និង Chung, ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។

[20] Fréderic Burnand, 'Uncovering the truth in the Killing Fields', *SwissInfo*, ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ (បញ្ជាក់បន្ថែម)

[21] សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ។

[22] ដូចខាងលើ ។

របស់គាត់ឱ្យបានត្រឹមត្រូវ និងដោយសេរីបានតទៅទៀតទេ ហើយគាត់បានប្រកាសពីការលាឈប់ដែលចូលជាធរមានចាប់ពីថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១២ តទៅ”[23] ។

៩. ការពិពណ៌នាអំពីស្ថានភាពចេញជារូបរាងឡើងនៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ។ ការពិពណ៌នាអំពីស្ថានការណ៍ទាំងនេះមានទម្រង់ជា “កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើទៅភាគី អំពីភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរារាំងដល់ការស៊ើបសួរឱ្យបានសមស្របនៅក្នុងសំណុំរឿង ០០៣ និង០០៤[24] (“កំណត់សម្គាល់”) ដែលមានកម្រាស់ ១៤ទំព័រ ពិពណ៌នាអំពីស្ថានការណ៍ជាក់ស្តែងចំនួនដប់ដែលមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ ដែលកើតឡើងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតចាប់តាំងពីការមកដល់របស់ចៅក្រម Kasper-Ansermet[25]។ បុគ្គលដែលមានឈ្មោះនៅក្នុងកំណត់សម្គាល់នេះ រួមមានចៅក្រម យូ ប៊ុនឡេង និងសឹងតែបុគ្គលិកកម្ពុជាទាំងអស់របស់គាត់, ចៅក្រម ប្រាក់ គឹមសាន, ឯកឧត្តម ក្រាញ់ តូនី (ប្រធានស្តីទីការិយាល័យរដ្ឋបាល), សមាជិកនានានៃផ្នែកគ្រប់គ្រងតុលាការ (រួមទាំងអ្នកបកប្រែនិងអ្នកបើកបរ) និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងមន្ត្រីនានានៅក្រសួងមហាផ្ទៃកម្ពុជា។

១០. អនុលោមតាមកំណត់សម្គាល់: (i)ទង្វើរបស់ចៅក្រម យូ ប៊ុនឡេង “បង្ហាញពីអត្ថិភាពនៃភាពមិនប្រក្រតីយ៉ាងធ្ងន់ធ្ងរ និងស្ថានការណ៍នៃភាពមិនអាចដំណើរការបានដែលរារាំងដល់ការស៊ើបសួរឱ្យបានសមស្រប”[26], (ii)ចៅក្រម Kasper-Ansermet មាន“ភារកិច្ចជូនដំណឹងដល់ភាគី [...] អំពី

[23] ដូចខាងលើ ។

[24] សំណុំរឿង ០០៣ និង០០៤, ឯកសារ D-38 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ERN 00791885–00791898 ។

[25] ស្ថានការណ៍ទាំងដប់ដែលត្រូវបានរៀបរាប់នៅក្នុងកំណត់សម្គាល់មានដូចតទៅ: (i) “ការបដិសេធរបស់ចៅក្រម យូ ប៊ុនឡេង មិនទទួលស្គាល់ ឬគាំទ្រឋានៈរបស់ចៅក្រម Kasper-Ansermet ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ” នៅកថាខណ្ឌទី១០ ដល់១៧, (ii) “នីតិវិធីដោះស្រាយលើការខ្វែងយោបល់នៅចំពោះមុខអង្គបុរេជំនុំជម្រះតាមវិធាន ៧២” នៅកថាខណ្ឌទី១៨ ដល់២៧”, (iii) “ភាពមិនប្រក្រតីនៅក្នុងដំណើរការចំពោះជិតចិត្តចៅក្រម ប្រាក់ គឹម សាន” នៅកថាខណ្ឌទី២៨ ដក់៣២, (iv) “ការបដិសេធមិនឱ្យ ដាក់ឯកសារទៅក្នុងសំណុំរឿង ដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ” នៅកថាខណ្ឌទី៣៣ ដល់ ៣៨, (v) “ការបដិសេធដើមបណ្តឹងរដ្ឋប្បវេណីមិនឱ្យចូលមើលសំណុំរឿង បន្ទាប់ពីមានដីកាសម្រេចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី” នៅកថាខណ្ឌទី ៣៩ ដល់៤០, (vi) “ការដកយកគ្រោះរបស់ កសចស” នៅកថាខណ្ឌ ៤១ដល់៤៣, (vii) “ការរារាំងការស៊ើបអង្កេតផ្ទៃក្នុង” នៅកថាខណ្ឌ ៤៤ ដល់៤៧, (viii) “ភាពមិនអាចសុំឱ្យបំពេញការងារនៃអ្នកបើកបរ និងអ្នកធ្វើប្រតិចារិត” នៅកថាខណ្ឌ៤៨, (ix) “មិនមានសហការពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ” នៅកថាខណ្ឌទី៤៩ ដល់៥០, និង (x) “នីតិវិធីមិនត្រឹមត្រូវនៅចំពោះគណៈ កម្មាធិការវិធាន និងនីតិវិធី” នៅកថាខណ្ឌ ៥១ ដល់៥៤ ។

[26] កំណត់សម្គាល់ នៅកថាខណ្ឌទី១ ។

ស្ថានការណ៍នៃភាពមិនអាចដំណើរការបានដែលប៉ះពាល់ដល់កិច្ចស៊ើបសួរសំណុំរឿងខាងលើ និង អំពីអសមត្ថភាពទាំងស្រុងដែលគាត់ និងការិយាល័យរបស់គាត់កំពុងប្រឈមនៅក្នុងការបំពេញ កាតព្វកិច្ចតាមផ្លូវច្បាប់ប្រកបដោយការយកចិត្តទុកដាក់ និងប្រសិទ្ធិភាព[27], (iii) ការរារាំងកិច្ចស៊ើប សួរក្នុងសំណុំរឿងខាងលើដោយចៅក្រម យូ ប៊ុនឡេង "ជាការរំលោភលើការអនុវត្តនីតិវិធីត្រឹម ត្រូវតាមច្បាប់ និងដំណើរការល្អនៃកិច្ចការតុលាការ"[28] (iv) ការសម្រេចមិនតែងតាំង [ចៅក្រម Kasper-Ansermet] ក្នុងមុខតំណែងជា អចិន្ត្រៃយ៍ [...] "គឺរំលោភមាត្រា៥ កថាខណ្ឌ៦ នៃកិច្ច ព្រមព្រៀង"[29]ហើយអ្វីដែលជាបញ្ហាធ្ងន់ធ្ងរ (v)*បុគ្គលិកកម្ពុជាគ្រប់កម្រិតទាំងអស់នៅតុលាការនេះ* ទទួលស្គាល់ និងទទួលយក "សិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ថា ជា*អ្នកសម្រេចតែម្នាក់គត់លើគោលនយោបាយនៅ កសចស*"[30]។

១១. ការទទួលស្គាល់ភាពមិនអាចកើតឡើងបាននៃតួនាទីរបស់គាត់ ចៅក្រម Kasper-Ansermet លើក ឡើងថា "មានភាពមិនប្រក្រតីយ៉ាងធ្ងន់ធ្ងរ ស្ថានភាពមិនអាចដំណើរការបាន និងការរំលោភនីតិវិធី ត្រឹមត្រូវ ដែលគ្រោះថ្នាក់ និងធ្វើឲ្យជាប់គាំងដល់ដំណើរការត្រឹមត្រូវនៃច្បាប់ ហើយស្ថានការណ៍ បានធ្វើឲ្យប៉ះពាល់ការស៊ើបសួរសមស្របក្នុងសំណុំរឿង ០០៣ និង០០៤"[31]។ អ្វីដែលបាន ពិពណ៌នានៅក្នុងសារព័ត៌មានជាភស្តុតាងនៃ "តុលាការមួយដែលបុគ្គលិកជាតិនៅគ្រប់កម្រិតបាន ប្រឹងប្រែងរារាំងកិច្ចការរបស់ចៅក្រម Kasper-Ansermet ក្រោមការបង្គាប់របស់សហចៅក្រម ស៊ើបអង្កេតជាតិ យូ ប៊ុនឡេង[32]" កំណត់សម្គាល់នេះ គឺជាចោទប្រកាន់យ៉ាងដំណំដែលមិនអាច ប្រកែកបានដល់ស្ថានប័នមួយដែលត្រូវបានអន្តរាយ និងអាប់យស ។

## គ. ប្រតិកម្មជាផ្លូវការ

---

[27] កំណត់សម្គាល់ នៅកថាខណ្ឌទី៦ ។

[28] កំណត់សម្គាល់ នៅកថាខណ្ឌទី៩ ។

[29] កំណត់សម្គាល់ នៅកថាខណ្ឌទី១៦ (សំអាងសេចក្តីព័ត៌មានរបស់អង្គការសហប្រជាជាតិចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១២) ។

[30] កំណត់សម្គាល់ នៅកថាខណ្ឌទី៤៥ (បញ្ជាក់បន្ថែម) ។

[31] ដូចខាងលើ នៅទំព័រ ១៣ (ផ្នែកសេចក្តីសន្និដ្ឋានបញ្ចប់) ។

[32] Julia Wallace & Kuch Naren, 'ចៅក្រមពិពណ៌នាអំពីភាពមិនអាចដំណើរការបាន" នៅតុលាការ" (Judge Details Dysfunction At Tribunal', *Cambodia Daily*, ចុះផ្សាយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ។ សូមផលដែរ Bridget Di Certo, 'Judge decries 003, 004 "sabotage"', *Phnom Penh Post*, ចុះផ្សាយនៅថ្ងៃទី២២ ខែនមីនា ឆ្នាំ២០១២ ("កំណត់សម្គាល់ ១៩ទំព័រ ចៅក្រមចុច ឈ្មោះបុគ្គលនានា និងពិពណ៌នា "ស្ថានភាពធ្ងន់ធ្ងរនៃភាពមិនអាចដំណើរការបានដែលរាំងស្ទះដល់ការ ស៊ើបសួរសមស្របក្នុង សំណុំរឿងពីរ ដែលជំទាស់ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន) ។

១២. ដូចដែលបានរំពឹងទុក ប្រតិកម្មនានាមកពីក្រុមឃ្លាំមើលតុលាការកើតមានជាហូរហែរ:

ក. ដែលធ្ងន់ធ្ងរបំផុត គឺជាការវាយតម្លៃរបស់អង្គការគំនិតផ្តួចផ្តើមសង្គមយុត្តិធម៌បើកចំហរ (OSJI)។ បើនិយាយពីអង្គការនេះវិញ អ្នកស្រី Clair Duffy ថ្កោលទោសការខកខានម្តងហើយម្តងទៀតរបស់អង្គការសហប្រជាជាតិ ក្នុងការមិនបានប្រើប្រាស់អំណាចឲ្យបញ្ឈប់ការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាដែលកើតមានជាច្រើនឆ្នាំមកហើយ: "បញ្ហាគឺថា បើមានបញ្ហាច្រើនមិនអាចដោះស្រាយបាន នោះវានឹងបង្កការអន្តរាយដល់ស្ថាប័ននេះ ហើយយើងដឹងថាបញ្ហាមួយចំនួននៃបញ្ហាទាំងនេះនៅក្នុងសំណុំរឿង ០០៣ និង០០៤ បានលាយឡំចូលគ្នាក្នុងសំណុំរឿង ០០២"[33]។ ការយោងទៅលើកំណត់កម្តល់ជាភស្តុតាងបញ្ជាក់ពីភាពអសកម្ម និង "ទង្វើខុសច្បាប់" របស់ចៅក្រម យូ ប៊ុនឡេង លោកស្រី Clair Duffy បានអំពាវនាវអង្គការសហប្រជាជាតិនិងប្រទេសផ្តល់ជំនួយក្រោកឈរ [...] និងដោះស្រាយចំណុចស្នូលនៃបញ្ហានេះ[34]។ នៅក្នុងសេចក្តីប្រកាសសារព័ត៌មានដែលប្រើពាក្យខ្លាំងៗ អង្គការ OSJI អំពាវនាវអង្គការសហប្រជាជាតិឲ្យពិចារណាឡើងវិញពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសាលាក្តីខ្មែរក្រហម[35]។ ដោយបានយោងទៅលើ "ស្ថានការណ៍ដែលនាំឲ្យអន្តរាយដូចដែលបានលើកឡើងនៅក្នុងកំណត់សម្គាល់អង្គការនេះបញ្ជាក់អំពីសំណួរដែលប្រឈមដោយអ្នកគាំទ្រអន្តរជាតិរបស់តុលាការ: អង្គការសហប្រជាជាតិត្រូវតែសម្រេចថា តើភាពជាដៃគូរបស់ខ្លួនដែលកំពុងបន្តនៅ អវតក គឺជាកិច្ចខិតខំប្រឹងប្រែងពិតប្រាកដ ដើម្បីស្វែងរកការពិត និងយុត្តិធម៌ដែរ ឬយ៉ាងណា ឬគ្រាន់តែជាអ្នកគាំទ្រអន្តរជាតិនៃដំណើរដែលត្រួតត្រាដោយរដ្ឋាភិបាលកម្ពុជា និងជម្រុញដោយនយោបាយនោះ។ [...]

---

[33] Julia Wallace, 'ចៅក្រមជាតិស្វីសលាឈប់ពីសាលាក្តីខ្មែរក្រហម" (Swiss judge quits Khmer Rouge Tribunal), *Cambodia Daily*, ចេញផ្សាយនៅថ្ងៃទី ២២ ខែមីនា ឆ្នាំ២០១២ (បញ្ជាក់បន្ថែម) ។ សូមមើលផងដែរ Irwin Loy 'សាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជាទទួលរងនូវសម្ពាធបន្ទាប់ចៅក្រមលាឈប់ (Cambodian War Crimes Tribunal Under Pressure After Judge Resigns), *Voice of America*, ផ្សាយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ "បញ្ហានៅទីនេះ គឺថាអង្គការសហប្រជាជាតិមិនបានធ្វើអ្វីជាដុំកំភួន ដើម្បី ដោះស្រាយអ្វីមួយដែលគេមើលឃើញថារដ្ឋាភិបាលកំពុងតែត្រួតត្រាលើតុលាការ" អ្នកស្រី Duffy មានប្រសាសន៍ "កាលពីឆ្នាំកន្លងទៅយើងស្នើសុំម្តងជាពីរដងឲ្យអង្គការសហប្រជាជាតិធ្វើការស៊ើបអង្កេតការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលទៅក្នុងតុលាការ តែ អង្គការនេះមិនបានស៊ើបអង្កេតទេ ។

[34] Bridget Di Certo, "រាំងស្ទះ" ចៅក្រមលាឈប់ពីតុលាការ: ចៅក្រមដែលតែងតាំងដោយអង្គការសហប្រជាជាតិលើកឡើងពី "ស្ថានភាពនៃភាពមិនអាចដំណើរការបាន" កាសែត ភ្នំពេញ ប៉ុស្ត៍, ផ្សាយថ្ងៃទី ២០ ខែមីនា ឆ្នាំ២០១២ ។

[35] សេចក្តីប្រកាសព័ត៌មានរបស់ OSJI "អង្គការសហប្រជាជាតិត្រូវពិចារណាឡើងវិញពីការប្តេជ្ញាចិត្តចំពោះសាលាក្តីខ្មែរក្រហម" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ។

លទ្ធផលអាក្រក់បំផុតនឹងធ្លាក់មកលើភាគីដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងបង្កើត អវតក ក្នុងការប្រើប្រាស់ការប្រខិតផ្លូវច្បាប់ ដើម្បីបិទបាំងឧបសគ្គខាងនយោបាយ និងហិរញ្ញវត្ថុ ដល់យុត្តិធម៌នៅកម្ពុជា"[36]។ ដែលត្រូវបានជួយគាំទ្រនៅគ្រប់ថ្នាក់នៅតុលាការនេះដោយបុគ្គលិកកម្ពុជាទាំងអស់ដែលបានឃើញសំណុំឯកសារនៅទូទាំងការស៊ើបអង្កេត"[37] ដូច្នេះចៅក្រម យូ ប៊ុនឡេង ត្រូវទទួលការស្តីបន្ទោស ហើយគាត់ជាឥស្សរជនដ៏សំខាន់ក្នុងការអនុវត្តផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា[38]។

ខ. អង្គការលើកលែងទោសអន្តរជាតិជម្រុញឱ្យអង្គការសហប្រជាជាតិ "ដាក់លក្ខខណ្ឌជាបន្ទាន់ដើម្បីឱ្យអង្គការនេះបន្តការពាក់ព័ន្ធរបស់ខ្លួននៅតុលាការ ដែលរួមមានបញ្ឈប់ការចូលជ្រៀតជ្រែកនយោបាយពីសំណាក់រដ្ឋាភិបាល"[39]។ ដោយបានសង្កត់ធ្ងន់ពីភាពគ្មានខ្លឹមសារនៃការគាំទ្រតិចតួច លោក Rupert Abott បានវាយតម្លៃដោយផ្ទាល់ "អ្វីដែលគ្រោះថ្នាក់នៅទីនេះគឺថាអង្គការសហប្រជាជាតិត្រូវជាអ្នកកាច់ចង្កូចដ៏សំខាន់នៃយុត្តិធម៌អន្តរ ។ ប្រសិនអង្គការសហប្រជាជាតិនៅបន្តប្រើពាក្យខ្លាំងៗ តែមិនមានចំណាត់ការណាមួយនោះ [...]

---

[36] ដូចខាងលើ ។

[37] Bridget Di Certo, "ចៅក្រមពិពណ៌នាថាសំណុំរឿង ០០៣ និង០០៤ "អន្តរាយ" កាសែត ភ្នំពេញ ប៉ុស្ត៍ ចុះផ្សាយថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១២ ("អ្នកស្រី Duffy នៃអង្គការ OSJI មានប្រសាសន៍ថា "វាជាការរន្ធត់ចិត្តបំផុតសំរាប់សំណុំរឿង ០០៣ និង០០៤ មិនអាចស្រោចស្រង់បានឡើយ"។ "វាបន្ថែមពីលើភស្តុតាងដែលមានស្រាប់ដែលបញ្ជាក់ថារដ្ឋាភិបាលត្រួតត្រាលើតុលាការ" អ្នកស្រី Duffy និយាយថា "ការថ្លែងជាធារណៈរបស់រដ្ឋាភិបាល ពេលនេះកំពុងក្លាយជាសកម្មភាពដោយបុគ្គលិកកម្ពុជានៅគ្រប់កម្រិតនៃតុលាការ ដែលបានមើលឃើញសំណុំឯកសារនៅទូទាំងការស៊ើបសួរ ។ ខ្ញុំមិនអាចដឹងនៅចំណុចនេះទេថាអង្គការសហប្រជាជាតិ មិនអាចធ្វើមិនដឹងមិនឮពីស្ថានការណ៍ដ៏អាក្រក់នេះ")។

[38] Julia Wallace & Kuch Naren, "ចៅក្រមពិពណ៌នាលំអិតពីស្ថានភាពមិនអាចដំណើរការបាននៅសាលាក្តី" កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ("ខ្លឹមសាររបស់ឯកសារនោះ គឺហាក់ដូចអន្តរាយបើនិយាយពីកម្រិតដែលផ្នែកជាតិ ធ្លាក់ក្នុងខ្សែរបន្ទាត់រដ្ឋាភិបាល ហើយ ចៅក្រម យូ ប៊ុនឡេង ជាឥស្សរជនសំខាន់ក្នុងការធ្វើឱ្យប្រាកដថាអ្វីគ្រប់យ៉ាងបានកើតឡើង ក៏ដូចជាមន្ត្រីរដ្ឋបាលជាន់ខ្ពស់នៅតុលាការផងដែរ" ។

[39] Julia Wallace "ចៅក្រមស្វីសលាឈប់ពីសាលាក្តីខ្មែរក្រហម" កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។ សូមមើលផងដែរ "កម្ពុជា: ហានិភ័យនៅសាលាក្តីខ្មែរក្រហមដោយសារចៅក្រមទីពីរលាឈប់" *អង្គការលើកលែងទោសអន្តរជាតិ* ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ "អង្គការសហប្រជាជាតិត្រូវតែទាមទារឱ្យរដ្ឋាភិបាលបញ្ឈប់ការជ្រៀតជ្រែកនយោបាយ និងធានាឱ្យបានច្បាស់ថាសកម្មភាពបែបនេះមិនត្រូវកើតឡើងតទៅទៀតនោះទេ" ដោយ Rupert Abbott ។

វាបង្ហាញថាការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាលនឹងឈ្នះ [...] ហើយនិទណ្ឌភាពនឹងឈ្នះលើការទទួលខុសត្រូវជាពុំខានឡើយ”[40]។

គ. អ៊ូរ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចុចចំចំណុចស្នូលរបស់បញ្ហាតែម្តងៈ ប្រសិនបើរដ្ឋាភិបាលមានឆន្ទៈបន្តរអូសបន្លាយការរារាំងសំណុំរឿងទាំងពីរ នោះមានន័យថារដ្ឋាភិបាលមិនចង់ឱ្យមានសំណុំរឿងនេះទេ។ ថាតើយើងមានទំនុកចិត្តយ៉ាងដូចម្តេច ខណៈដែលលទ្ធផលនៃសំណុំរឿង ០០១ និង០០២ ត្រូវបានកំណត់រួចជាស្រេចមកហើយនោះ?[41]។ ការអធិប្បាយបែបនេះលើកឡើងពីអ្វីមួយដែលជាការភ័យខ្លាចបំផុតរបស់អង្គការសហប្រជាជាតិទាក់ទងនឹង អវតក ដែលត្រូវបានបញ្ចេញ កាលពីឆ្នាំកន្លងទៅដោយអគ្គលេខាធិការរងទទួលបន្ទុកកិច្ចច្បាប់នៃអង្គការប្រជាជាតិ អ្នកស្រី Patricia O'Brien: “អង្គការសហប្រជាជាតិ [មិន] ចង់ឱ្យមានការស៊ើបសួរឡើយ ដោយសារតែការស៊ើបសួរនេះអាចប៉ះពាល់ដល់សំណុំរឿង ០០២ ដែលតុលាការកំពុងជំនុំជម្រះ”[42]

ឃ. ដូចគ្នានឹង OSJI, Amnesty និង CCHR ដែរអង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានអំពាវនាវឱ្យអង្គការសហប្រជាជាតិពិចារណាឡើងវិញក្នុងការឆ្លើយតបទៅនឹងការបង្ហើបឱ្យដឹងចុងក្រោយនេះ[43] ហើយបុគ្គលដទៃទៀតបង្ហាញពីបញ្ហាខាងក្រោមៈ “នេះជាការជ្រៀតជ្រែកខាងនយោបាយយ៉ាងច្បាស់ក្រឡែត។ វាគឺជាការការពារខ្លួនអ្នក” នេះជាការកត់

---

[40] Bridget Di Certo, “ការចាកចេញរបស់ចៅក្រមធ្វើឱ្យរង្គោះរង្គើរដល់តុលាការ” កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។

[41] Julia Wallace & Kuch Naren, “អង្គការសហប្រជាជាតិ “បារម្ភ” អំពីការលាឈប់របស់ចៅក្រម” កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។ សូមមើលផងដែរ Bridget Di Certo, “ការចាកចេញរបស់ចៅក្រមធ្វើឱ្យរង្គោះរង្គើរដល់តុលាការ” កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ (“បើទោះបីជាមានការធានាពីអង្គការសហប្រជាជាតិដែលថា ការចោទប្រកាន់ពីការជ្រៀតជ្រែកនយោបាយ ត្រូវបានដោះស្រាយ ក៏យើងនៅតែមើលឃើញថាការលាឈប់របស់ចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់ទៀត គឺដោយមូលហេតុការជ្រៀតជ្រែកនយោបាយ ។ វាមិនអាចទទួលយកបានទេ ។

[42] Julia Wallace & Kuch Naren, “អង្គការសហប្រជាជាតិ “បារម្ភ” អំពីការលាឈប់របស់ចៅក្រម” កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។

[43] សូមមើល Bridget Di Certo, “ការចាកចេញរបស់ចៅក្រមធ្វើឱ្យរង្គោះរង្គើរដល់តុលាការ” កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ (“អង្គការសហប្រជាជាតិត្រូវគិតយ៉ាងយកចិត្តទុកដាក់អំពីថា តើត្រូវបន្តការចូលរួមរបស់ខ្លួននៅក្នុងការកាត់ ទោសខ្មែរក្រហម” Brad Adams នាយក HRW ប្រចាំអាស៊ី)។

សម្គាល់ដោយអ្នកឃ្លាំមើលតុលាការ Henri Locard, ដោយបាននិយាយសំដៅទៅលើមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា[44]។ មេដឹកនាំគណបក្សប្រឆាំងលោក សម រង្ស៊ី បង្ហាញជំហរច្បាស់លាស់ជាងដោយបានពន្យល់ថាលោក ហ៊ុន សែន និងបក្សពួករបស់គាត់ "ភ័យខ្លាចពីការស៊ើបសួរធ្ងន់ធ្ងរ។ ការស៊ើបសួរធ្ងន់ធ្ងរនិងស៊ីជម្រៅ នឹងបង្ហាញឲ្យឃើញថាសមាជិកជាច្រើននៃរដ្ឋាភិបាលបច្ចុប្បន្នពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម [...] ។ ហេតុដូច្នេះហើយទើបសមាជិកជាច្រើននៃរដ្ឋាភិបាលបច្ចុប្បន្ន [រួមទាំង ហេង សំរិន ជា ស៊ីម[45]] បដិសេធមិនផ្តល់សក្ខីកម្មតាមការកោះហៅ"[46]។

ដោយបញ្ចប់ស្ថានភាពដ៏ពិបាករបស់គាត់ ចៅក្រម Kasper-Ansermet សង្កត់ធ្ងន់ពីការរារាំងរបស់រាជរដ្ឋាភិបាលកម្ពុជា: "ខ្ញុំត្រូវបានរារាំងនៅគ្រប់ទិដ្ឋភាពទាំងអស់ [...] ។ វាជាសកម្មភាពខុសច្បាប់ហើយខ្ញុំមិនអាចទ្រាំបាននូវស្ថានការបែបនេះតទៅទៀតទេ"[47]។ នៅក្នុងការអធិប្បាយផ្លូវការចុងក្រោយរបស់គាត់នៅពេលដាក់កំណត់សម្គាល់នេះ ចៅក្រមបានធ្វើការកត់សម្គាល់យ៉ាងក្រេវ

---

[44] "ចៅក្រមទីពីរលាឈប់ពីសាលាក្តីខ្មែរក្រហម" *Reuters*, ចុះផ្សាយថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ ។

[45] កំណត់សម្គាល់៖ លោក ហេង សំរិន និងលោក ជា ស៊ីម ត្រូវបានធ្វើឲ្យជាប់ពាក់ពាន់ក្នុងរបបកម្ពុជាប្រជា ធិបតេយ្យ ហើយបញ្ហានេះគឺស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក។ សូមមើល Stephen Heder "ការវាយតម្លៃសារជាថ្មីអំពីតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ និងមន្ត្រីមូលដ្ឋានក្នុងឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ: "Cambodian Accountability in Comparative Perspective" ចុះខែមិនា ឆ្នាំ២០០៣ ERN 00661455–00661491, n 207 (ភស្តុតាងផ្សេងៗដែលធ្វើឲ្យលោក ហេង សំរិន ជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មសង្គ្រាមការសម្លាប់រង្គាលទៅលើជនស៊ីវិលវៀតណាមដែលធ្វើឡើងដោយកងទ័ពក្រោមបញ្ជារបស់គាត់ក្នុងអំឡុងពេលការវាយប្រហារកាត់ព្រំដែនចូលទៅក្នុងប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៧) និង n 208 (លោក ជា ស៊ីម ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវលើការសម្លាប់ប្រជាជនថ្មី និងប្រជាជនដទៃទៀតក្នុងស្រុក ពញាក្រែក តំបន់ ២០ នៅបូព៌ា ដែលនៅទីនោះគាត់ធ្វើជាលេខា[...]អ្នកឲ្យការណ៍ក្នុងស្រុកប៉ាន់ស្មានថាមានប្រជាជនរាប់ពាន់អ្នកត្រូវបានសម្លាប់ក្នុងមន្ទីរសន្តិសុខស្រុកពញាក្រែក ដែលនៅពេលនោះ លោក ជា ស៊ីម ធ្វើជាលេខាស្រុក ហើយការសម្លាប់នោះធ្វើឡើងយ៉ាងសាហាវបំផុតក្រោមការគ្រប់គ្រងរបស់គាត់នៅចុងឆ្នាំ១៩៧៧និងដើមឆ្នាំ១៩៧៨)។ បញ្ហាទាំងនេះត្រូវបានលើកឡើងក្នុងតុលាការដោយមេធាវីការពារក្តី។ សូមមើលឯកសារ No **E-1/39.1** សូមមើលប្រតិចារិកនៃដំណើរការនីតិវិធីជំនុំជម្រះ, ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ២០១២ (ថ្ងៃសវនាការ ២៧) ERN 00778068–00778180, p 72:20–22 and pp 72:24–73:7។ ទំព័រទាំងនេះត្រូវបានភ្ជាប់មកជាមួយ។

[46] មេដឹកនាំគណបក្សប្រឆាំងលើកឡើងពីការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ" វទ្យុសម្លេងអាមេរិកកាំង" ចុះផ្សាយទី១៩ ខែមីនា ឆ្នាំ២០១២ ។

[47] សូមមើល Bridget Di Certo, ចៅក្រមដែលត្រូវ "ការរារាំង" លាឈប់ពីតុលាកា, *កាសែតភ្នំពេញប៉ុស្ត* ចុះផ្សាយនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១២ ។

ក្រោធ: "ដោយប្រឈមជាមួយនឹងអរិយភាពពីសំណាក់ចៅក្រមកម្ពុជា ការស្ងៀមស្ងាត់នៃសហការីអន្តរជាតិរបស់ខ្ញុំ និងការងាកចិត្តពីការខាងរដ្ឋបាល ធ្វើឱ្យខ្លួនពិបាកគិត[48]។

១៣. ការឆ្លើយតបភ្លាមៗរបស់អង្គការសហប្រជាជាតិមានលក្ខណៈប្រយ័ត្នប្រយែង: "ស្ថានភាពនៅអវតក បន្តឱ្យមាននូវក្ដីកង្វល់ធ្ងន់ធ្ងរខ្លាំងឡើងៗ ហើយយើងកំពុងតែត្រួតពិនិត្យតាមដានបញ្ហានេះយ៉ាងយកចិត្តទុកដាក់ជាទីបំផុត"[49]។ បន្ទាប់មកត្រូវបានគេប្រកាសថា អង្គការកំពូលមួយនេះកំពុងតែវាយតម្លៃស្ថានការនេះ ដោយមានជំនួយពីលោក David Scheffer[50] ។ លោក Scheffer កាលពីពេលកន្លងទៅបានបង្ហាញសុទិដ្ឋិនិយម (ទាំងឆោតល្ងង់) ថាចៅក្រម Kasper-Ansermet អាចស៊ើបអង្កេតសំណុំរឿងទាំងពីរនេះយ៉ាងពេញលេញ[51]។ នៅពេលដាក់សំណើនេះលោក Scheffer មិនធ្វើការអធិប្បាយផ្លូវការទេ[52]។ ប៉ុន្តែអគ្គលេខាធិការអង្គការសហប្រជាជាតិបញ្ជាក់ពី

---

[48] Julia Wallace "សេចក្ដីស្រឡាញ់ពីភ្នំពេញ" *International Justice Tribune*, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ។

[49] នាយកដ្ឋានព័ត៌មានអង្គការសហប្រជាជាតិ Daily Press Briefing ដោយការិយាល័យអ្នកនាំពាក្យរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សូមមើលផងដែរ ចៅក្រមស្វីសលាឈប់ពីសាលាក្ដីខ្មែរក្រហម" កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។ ("អ្នកនាំពាក្យលោកអគ្គលេខាធិការមិនបានឆ្លើយតបទៅនឹងសំណើសុំការធ្វើអធិប្បាយ) ។ Julia Wallace & Kuch Naren, "អង្គការសហប្រជាជាតិ "បារម្ភ" អំពីការលាឈប់របស់ចៅក្រម" កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ("សេចក្ដីថ្លែងការរបស់អង្គការសហប្រជាជាតិខ្លី មានអត្ថន័យខ្លាំងជាងការឆ្លើយតបរបស់ ចំពោះការលាឈប់របស់ចៅក្រម Siegfried Blunk កាលពីខែតុលា ឆ្នាំ២០១១ ដែលបានលើកឡើងពីការជ្រៀតជ្រែកនយោបាយក្នុង សំណុំរឿង ០០៣ និង០០៤ ដែរ ។ នៅពេលនោះ អង្គការសហប្រជាជាតិគ្រាន់តែមានអរគុណាចៅក្រម Siegfried Blunk ចំពោះកិច្ច ការរបស់គាត់) ។ Bridget Di Certo, "ការចាកចេញរបស់ចៅក្រមធ្វើឱ្យរង្គោះរង្គើរដល់តុលាការ" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ("នៅក្នុងការប្រកាសព័ត៌មានខ្លីកាលពីម្សិលមិញ Eduardo del Buey អ្នកនាំពាក្យរងរបស់ លោកអគ្គលេខាធិការអង្គការប្រជាជាតិ Ban Ki-moon និយាយថាអង្គសហប្រជាជាតិកំពុតែត្រួតពិនិត្យស្ថានការនៅ អវតក យ៉ាង យកចិត្តទុកដាក់ តែមិននិយាយអ្វីឱ្យលើសពីនេះទេ) ។

[50] Julia Wallace "អង្គការប្រជាជាតិបញ្ជាក់ពីក្ដីបារម្ភរបស់ខ្លួនឡើងលើស្ថានការណ៍នៃភាពដែលមិនអាចដំណើរការបាននៅសាលាក្ដីខ្មែរក្រហម កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ។

[51] Julia Wallace "ចៅក្រមស្វីសលាឈប់ពីសាលាក្ដីខ្មែរក្រហម" កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ។

[52] ដូចខាងលើ ("David Scheffer, អ្នកជំនាញដែលទើបតែងតាំងដោយអង្គការសហប្រជាជាតិបដិសេធមិនធ្វើការអធិប្បាយលើការលាឈប់របស់ចៅក្រមទេ) ។ Bridget Di Certo, ""ចៅក្រមពិពណ៌នាថាសំណុំរឿង ០០៣ និង០០៤ "អន្តរាយ" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១២ ("ការិយាល័យអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិមិនឆ្លើយតប ទៅនឹងសំណើសុំការធ្វើអធិប្បាយ ហើយអ្នកជំនាញការពិសេសលោក David Scheffer ក៏មិនឋិតនៅក្នុងប្រទេសដែរ)។

ជំហររបស់ខ្លួនឡើងវិញថា "សេចក្តីសម្រេចមិនតែងតាំងចៅក្រម Kasper-Ansermet ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅ អវតក គឺរំលោភ [...] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា" ដោយបានគូសបញ្ជាក់បន្ថែមទៀតថា "ការខកខានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាក្នុងការមិនយល់ព្រមលើការតែងតាំងនេះ បង្កើតឱ្យមានភាពទ័លច្រកបច្ចុប្បន្ននេះ"[53]។

១៤. ខណៈដែលតុលាការខ្លួនឯងមិនអាចផ្តល់ការឆ្លើយតបជាផ្លូវការ[54] ជាបឋមចៅក្រម យូ ប៊ុនឡេង ព្យាយាមនិយាយសម្រាលពីស្ថានការណ៍ស្របតាមបន្ទាត់នយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា: "ខ្ញុំមិនបានរារាំងគាត់ទេ ខ្ញុំគ្រាន់តែមិនទទួលស្គាល់ការងាររបស់គាត់ ហើយខ្ញុំបានប្រាប់គាត់ថា អ្វីដែលគាត់កំពុងតែធ្វើ គឺមិនស្របតាមនីតិវិធីច្បាប់ទេ"[55]។ ក្រោយមកគាត់ចេញប្រតិកម្មជាផ្លូវការយ៉ាងវែង ដោយបានស្វាគមន៍ការចាកចេញរបស់ចៅក្រម Kasper-Ansermet[56]។ "ការវាយតបបែបរសឹបរសៀវ ដែលបានបង្ហើបឱ្យដឹងគួរឱ្យចម្លែក"[57] ការឆ្លើយតប"បញ្ជាក់ពីការរៀបរាប់ [របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង] អំពីស្ថានការណ៍ដែលភាពមិនអាចដំណើរការនៅក្នុងការិយាល័យដែលបង្កឡើងដោយការខ្វែងគំនិតគ្នារវាងបុគ្គលិកជាតិ និងអន្តរជាតិ"[58]។ គាំទ្រដល់សហការីរបស់ពួកគេនៅ កសចស ចៅក្រមកម្ពុជានៅអង្គបុរេជំនុំជម្រះបានចេញសេចក្តីថ្លែ

---

[53] Bridget Di Certo, "សាលាក្តីខ្មែរក្រហម គឺជាតុលាការគំរូ" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១២ ។

[54] Bridget Di Certo, "ការចាកចេញរបស់ចៅក្រមធ្វើឱ្យរង្គោះរង្គើរដល់តុលាការ" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២១ ខែ មីនា ឆ្នាំ២០១២ ("ដោយសារតុលាការមានអង្គជំនុំជម្រះ និងស្ថាប័នឯករាជ្យជាច្រើន ហេតុដូច្នេះវាមិនអាចផ្តល់ការឆ្លើយតបតែមួយទៅនឹង សំណួរនេះ") (សម្រង់ចេញពីសម្តីរបស់អ្នកនាំពាក្យកិច្ចការច្បាប់នៅ អវតក Lars Olsen) ។ Julia Wallace "ចៅក្រមស្វីសលាឈប់ពីសាលាក្តីខ្មែរក្រហម" កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ("ពុំមានចៅក្រមបម្រុង ។ គាត់ជាចៅក្រមបម្រុង") ។

[55] Bridget Di Certo, "ការចាកចេញរបស់ចៅក្រមធ្វើឱ្យរង្គោះរង្គើរដល់តុលាការ" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២១ ខែ មីនា ឆ្នាំ២០១២ ។ សូមមើលផងដែរ Bridget Di Certo, ចៅក្រមដែលត្រូវ "ការរារាំង" លាឈប់ពីតុលាការៈ ចៅក្រមដែលតែងតាំងដោយអង្គការសហប្រជាជាតិលើកឡើងពី "ស្ថានការណ៍នៃភាពដែលមិនអាចដំណើរការបាន" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១២ ។

[56] សូមមើលសេចក្តីប្រកាសព័ត៌មានដោយសហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ។

[57] Julia Wallace, "ចៅក្រម យូ ប៊ុនឡេង វាយតបវិញទៅកាន់ការចោទប្រកាន់របស់ចៅក្រមស្វីស កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ។

[58] ដូចខាងលើ សូមមើលផងដែរ Bridget Di Certo & Cheang Sokha, "ហានិភ័យផ្នែកសុវត្ថិភាពនៅសាលាក្តីខ្មែរក្រហម" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ។

ងការមួយដោយបានវាយប្រហារមកលើចៅក្រម Kasper-Ansermet ថាជា "អ្នកប្រឌិតរឿង" ដែលបង្កបញ្ហាដោយឥតអៀនខ្មាស់ដល់តុលាការ ហើយសេចក្តីថ្លែងការណ៍នោះបានចោទថា ចៅក្រម Kasper-Ansermet មិនមែនជាចៅក្រមពិតទេ"[59]។

១៥. អ្នកនិយាយជំនួសឲ្យរាជរដ្ឋាភិបាលកម្ពុជា អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី ឯក ថា បានចេញមុខមកបដិសេធៈ"អ្វីដែលខ្ញុំអាចនិយាយបាន គឺថារាជរដ្ឋាភិបាលកម្ពុជាច្បាស់ណាស់ និងមិនដែលបាន និងមិនជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់ អវតក ឡើយ"[60]។ រាជរដ្ឋាភិបាលកម្ពុជាមិនដែលរំលោភកិច្ចព្រមព្រៀងណាមួយជាមួយអង្គការសហប្រជាជាតិនោះឡើយ"[61]។ "ខ្ញុំសូមសង្កត់បញ្ជាក់ថារាជរដ្ឋាភិបាលកម្ពុជាមិនឃើញថាមានបញ្ហានៅក្នុង អវតក ឡើយ [...] ។ រដ្ឋាភិបាលកម្ពុជាយល់ឃើញថាភាគីកម្ពុជាមិនរំលោភបទបញ្ជាផ្ទៃក្នុងណាមួយនោះទេ[62]។ វាហាក់ដូចជាការអង្កេតព្រឹត្តិការណ៍លើភពដទៃទៀតដែរ គាត់បានបន្ថែម "ក្នុងទស្សនរបស់គាត់ តុលាការនេះជាតុលាការគំរូ ហើយភាគីកម្ពុជានិងអង្គការសហប្រជាជាតិកំពុងតែធ្វើការជាមួយគ្នា ដើម្បីធានាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នឹងមិនកើតឡើងសារជាថ្មីឡើយ"[63]។ ត្រឡប់មកភពផែនដីវិញ គាត់និយាយពីរដ្ឋាភិបាល"អ្វីដែលនាយករដ្ឋមន្ត្រីនិយាយ ខ្ញុំគោរពតាមសេចក្តីសម្រេចរបស់គាត់"[64]។

## III. អង្គច្បាប់ពាក់ព័ន្ធ

## ក. ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ

[59] Julia Wallace, "ចៅក្រម យូ ប៊ុនឡេង វាយតបវិញទៅកាន់ការចោទប្រកាន់របស់ចៅក្រមស្វីស កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ។

[60] Bridget Di Certo, ចៅក្រមដែលត្រូវ "ការរារាំង" លាឈប់ពីតុលាការៈ ចៅក្រមដែលតែងតាំងដោយអង្គការសហប្រជាជាតិ លើកឡើងពី "ស្ថានការណ៍នៃភាពដែលមិនអាចដំណើរការបាន" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១២ ។

[61] Julia Wallace "អង្គការប្រជាជាតិបញ្ជាក់ពីក្តីបារម្ភរបស់ខ្លួនឡើងលើស្ថានការណ៍នៃភាពដែលមិនអាចដំណើរការបាននៅសាលាក្តីខ្មែរក្រហម កាសែត *Cambodia Daily*, ចេញផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២ ។

[62] Bridget Di Certo, "សាលាក្តីខ្មែរក្រហម គឺជាតុលាការគំរូ" កាសែត ភ្នំពេញ ប៉ុស្ត ចុះផ្សាយថ្ងៃទី២៣ ខែ មីនា ឆ្នាំ២០១២ ។

[63] ដូចខាងលើ ។

[64] ទិន្នន្ទភាពនៅសាលាក្តីខ្មែរក្រហមនឹងមិនត្រូវបានលើកលែងឡើយៈ អង្គការសហប្រជាជាតិ *Agence France Presse*, ចុះផ្សាយថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១២ ។

១៦. ដើម្បីសន្សំពេលវេលា មេធាវីការពារក្តីសូមដាក់បញ្ចូលសារណាផ្នែកច្បាប់ដែលមាននៅក្នុងបណ្តឹងសារទុក្ខភ្លាមៗពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ[65] និង "សំណើសុំមានចំណាត់ការសង្ខេបប្រឆាំងលោក ហ៊ុន សែន" ដែលបានដាក់នៅពេលថ្មីៗនេះ អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង[66]។ ជាងនេះទៅទៀត នៅពេលថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញដូចខាងក្រោមនេះ៖

> សមត្ថកិច្ចផ្នែកតុលាការលើរឿងក្តីនៅ អវតក ត្រូវបានបែងចែកទៅតាមដំណាក់កាលនៃ រឿងក្តីនីមួយៗ។ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះមានសមត្ថកិច្ចក្នុងដំណាក់ កាលស៊ើប អង្កេត ខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មានសមត្ថកិច្ច
> ក្នុងដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ។
>
> *ប្រសិនបើអនុវត្តឲ្យបានតឹងរឹងចំពោះសំណើយោងតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង ការបែកចែកសមត្ថកិច្ចនេះនឹងធ្វើឲ្យប៉ះពាល់ដល់ការទទួលខុសត្រូវរបស់តុលាការ ក្នុងការធានាដល់សុចរិតភាពនៃដំណើរការនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ*[67]។

ដូច្នេះ វាគ្មានមន្ទិលសង្ស័យអ្វីទេដែលថា អង្គជំនុំជម្រះនេះ អាច (និងគួរតែ) ចាត់វិធានការដោយសេរី ស្របតាម "ឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់ខ្លួន" ក្រោមវិធាន៣៥[68] ដើម្បីជាប្រយោជន៍ដល់ការធានាឲ្យមានភាពស្របច្បាប់នៃដំណើរការនីតិវិធី។

---

[65]បណ្តឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌទី១៥ ដល់១៨។

[66] ឯកសារលេខ **E-176**, ERN 00782947–00782959 , កថាខណ្ឌទី៨ ដល់ទី១០។

[67] ឯកសារលេខ **E-116/1/6** , ការសង្ខេបសំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗរបស់លោក នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២, ERN 00772881–00772887 , កថាខណ្ឌ១៤ (គូសបញ្ជាក់បន្ថែម) (ដកស្រង់ឯកសារលេខ **D-314/1/12**) "សេចក្តីសម្រេចលើកទី២ លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា និង អៀង សារី ប្រឆាំង ដីកាសម្រេចរបស់ កសចស លើសំណើសុំកោះហៅសាក្សី", ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០, ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Catherine Marchi-Uhel និងចៅក្រម Rowan Downing កថាខណ្ឌទី១០ ដល់១២)។

[68]បណ្តឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌទី១៥។

## ខ. កាតព្វកិច្ចតាមក្រមសីលធម៌របស់ចៅក្រម និងមេធាវីដើម្បីធានាភាពស្របច្បាប់ នៃដំណើរការនីតិវិធី

១៧. មេធាវីការពារក្ដីសូមដាក់បញ្ចូលសេចក្ដីសន្និដ្ឋានផ្នែកច្បាប់របស់ខ្លួនកាលពីមុនលើបញ្ហានៃឯករាជ្យភាពរបស់តុលាការ[69]។ បន្ថែមលើនេះទៅទៀត មាត្រា១ នៃក្រមសីលធម៌ចៅក្រមនៅ អវតក គឺពាក់ព័ន្ធទៅនឹងសំណើខាងលើនេះ៖

> ១.ចៅក្រមត្រូវរក្សានូវឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុង អវតក ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាពក្នុងការបំពេញ តួនាទីរបស់ ខ្លួន។
> ២.ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាការជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួន[70]។

ដោយស្មើភាពគ្នា ក្នុងនាមជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មេធាវីការពារក្ដីជនជាប់ចោទ មានកាតព្វកិច្ចការពារផលប្រយោជន៍កូនក្ដីរបស់ខ្លួនដោយចាត់វិធានការនានា ដើម្បីធានាឲ្យបាននូវដំណើរការនីតិវិធីស្របច្បាប់។ យោងតាមមាត្រា១៦ នៃក្រមសីលធម៌មេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា "មេធាវីត្រូវដឹងឲ្យច្បាស់ ថាកិច្ចប្រតិបត្តិការនោះស្ថិតនៅក្នុងក្របខ័ណ្ឌធានាវ៉ាប់រងពីពីក្រុមហ៊ុនដែលធានាវ៉ាប់រងចំពោះខ្លួន"។ ពិតណាស់ មេធាវីអន្តរជាតិនៅ អវតក ក៏ត្រូវចងដោយលក្ខខណ្ឌនៃក្រមសីលធម៌ក្នុងស្រុករៀងៗខ្លួនដែរ ដែលប្រហែលជាតម្រូវឲ្យមានវិធានការមុតមាំជាងនេះទៀត។ ដូចដែលបានលើកឡើងកាលពីមុន វាអាចមានចំណុចមួយដែលមេធាវីការពារក្ដី "ជួបការលំបាកក្នុងការប្រាប់ [កូនក្ដីរបស់ខ្លួន] ទាក់ទងនឹងបញ្ហាថាតើការបន្តចូលរួមរបស់គាត់ក្នុងការជំនុំជម្រះក្ដីនេះត្រូវបានធានាដែរ ឬអត់[71]"។

## គ. អំណាចក្នុងការផ្អាកដំណើរការនីតិវិធី

---

[69] សូមមើលឧទាហរណ៍, ឯកសារលេខ **E-171**, បណ្ដឹងជំទាស់លើកទី៣ប្រឆាំងចៅក្រម Carwright , ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១២, ឯកសារ ERN 00778399–00778412, កថាខណ្ឌទី៥។

[70] ក្រមសីលធម៌ចៅក្រមរបស់ អវតក, មាត្រា១។

[71]បណ្ដឹងសារទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ៣៩, សូមមើលផងដែរក្រមសីលធម៌មេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១៦ (ប្រសិនបើយល់ព្រម [ទទួលជួយ] មេធាវីត្រូវបំពេញបេសកម្មរបស់ខ្លួនរហូតដល់ទីបញ្ចប់ លើកលែងតែត្រូវដោះបន្ទុកវិញដោយអតិថិជន។ ដោយសារបុព្វហេតុដែលចេញពីសម្បជញ្ញៈរបស់ខ្លួន មេធាវីអាចសម្រេចបញ្ឈប់បេសកកម្មរបស់ខ្លួន តែត្រូវជូនដំណឹងទៅ អតិថិជនក្នុងពេលវេលាមួយដែលផ្ដល់លទ្ធភាពឲ្យអតិថិជននេះអាចបង្កាផលប្រយោជន៍របស់ខ្លួនបាន

១៨. ទាំងយុត្តិសាស្ត្រអន្តរជាតិនិងយុត្តិសាស្ត្រតនៅអវតក ទទួលស្គាល់ថានៅក្នុងតួនាទីរបស់ខ្លួនជាអ្នកត្រួតត្រាដំណើរការតុលាការ តុលាការមានអំណាចឆន្ទានុសិទ្ធិក្នុងការផ្អាកដំណើរការនីតិវិធីជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍នៅពេលដែលមានការចោទប្រកាន់អំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែល "នឹងស្តែងឲ្យឃើញពីការប៉ះពាល់ដល់សុចរិតភាពរបស់តុលាការ"[72]។ ជាការពិតណាស់កាលពីលើកមុន ដោយផ្អែកលើករណី *Lubanga* និងអាជ្ញាធរដទៃទៀត អង្គបុរេជំនុំជម្រះបានយល់ឃើញថា ចំណាត់ការបែបនេះនឹងចាំបាច់ក្នុងករណីពិសេស និងធ្ងន់ធ្ងរបំផុតទាក់ទងនឹងការរំលោភសិទ្ធិរបស់ជនជាប់ចោទដែលមិនអាចកែតម្រូវបាន ឬរំលោភទៅនឹងយុត្តិធម៌ពិតប្រាកដរបស់តុលាការ[73]។ ក្នុងកាលៈទេសៈបែបនេះ អង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុថា វាអាស្រ័យលើតុលាការក្នុងការធ្វើឲ្យមានតុល្យភាពយ៉ាងត្រឹមត្រូវរវាងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ និងផលប្រយោជន៍របស់សហគមន៍ជាតិ និងអន្តរជាតិ ក្នុងការកាត់ទោសជនដែលត្រូវបានចោទប្រកាន់ពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សធម៌អន្តរជាតិនិងច្បាប់ជាតិ[74]។ តុលាការកំពូលនៅ ICTY បានគូសបញ្ជាក់ថា៖ "ក្នុងកាលៈទេសៈដែលមានការគំរាមកំហែងសាក្សី [...] វាជាការទទួលខុសត្រូវអង្គជំនុំជម្រះដែលត្រូវប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីធានាថាការជំនុំជម្រះដោយយុត្តិធម៌អាចកើតឡើងបាន[75]"។ ការប្រឆាំងទៅនឹងការជ្រៀតជ្រែកបែបនេះតម្រូវឲ្យមានចំណាត់ការជាបន្ទាន់ ជាពិសេសនៅពេលដែលកម្លាំងពីខាងក្រៅចង់បំផ្លាញសមត្ថភាពរបស់ភាគីមួយក្នុងការបង្ហាញភស្តុតាងនៅក្នុងសវនាការ។ ដើម្បីឲ្យតុលាការនេះដំណើរការទៅមុខ

[72] សូមមើលរឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Radovan Karadzic*, No IT-95-5/18-AR73.4, សេចក្តីសម្រេចលើបណ្តឹងសារទុក្ខរបស់ Karadzic ប្រឆាំងនឹងសេចក្តីសម្រេចអង្គជំនុំជម្រះលើកិច្ចព្រមព្រៀង Holbrooke , ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩, កថាខណ្ឌ៤៥។ ឯកសារ **D-264/2/6**, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ច្រានចោលសំណើសុំផ្អាកដំណើរការនីតិវិធីដោយមូលហេតុរំលោភដំណើរការនីតិវិធី, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០, ឯកសារ ERN 00543794–00543799 , កថាខណ្ឌ២២ ដល់២៨។ សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Thomas Lubanga Dyilo*, Case No ICC-01/04-01/06, "សេចក្តីសម្រេចជាសាធារណៈដែលមានការកោសលុបលើលើសំណើបន្ទាន់របស់អយ្យការសុំផ្លាស់ប្តូរពេលវេលា កំណត់ដើម្បីបង្ហាញពីអត្តសញ្ញាណរបស់អន្តរការី១៤៣ ឬជាជម្រើសមួយផ្សេងទៀតត្រូវផ្អាកដំណើរការនីតិវិធី, ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌ៣១"។

[73] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ច្រានចោលសំណើសុំផ្អាកដំណើរការនីតិវិធីដោយមូលហេតុរំលោភដំណើរការនីតិវិធី, កថាខណ្ឌ២៨។

[74] *ដូចជើងទំព័រខាងលើ*។

[75] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Haradinaj et al*, Case No IT-04-84-A , សាលក្រមចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌ ៣៥។

ប្រកបដោយប្រសិទ្ធិភាព អង្គជំនុំជម្រះសាលាដំបូងត្រូវតែប្រឆាំងទៅនឹងការគំរាមកំហែងសាក្សី ដោយចាត់វិធានការណ៍ទាំងអស់ដែលសមស្រប និងដោយបើកចំហរ [...][76]។

## IV. អំណះអំណាង[77]

## ក. កំណត់សម្គាល់នេះបង្ហាញពីភាពច្បាស់លាស់ដែលថាមន្ត្រីកម្ពុជានៅ អវតក រួមបញ្ចូលទាំងចៅក្រមផងដែរ គឺធ្វើតាមការតួសវាសរបស់រដ្ឋាភិបាល

១៩. ការលាលែងចេញពីតំណែងរបស់ចៅក្រមបម្រុងអន្តរជាតិ Kasper-Ansermet និងកំណត់សម្គាល់របស់គាត់ គឺជាភស្តុតាងយ៉ាងច្បាស់ក្រឡែតដែលបង្ហាញថាគ្មានមន្ត្រីកម្ពុជាណាម្នាក់នៅ អវតក អាចអនុវត្តន៍ប្រឆាំងទៅនឹងរបៀបវារៈផ្ទៃកតុលាការរបស់រដ្ឋាភិបាលកម្ពុជាបានឡើយ។ ដោយមានទំហំធំធេង ឥទ្ធិពលរបស់រដ្ឋាភិបាលកម្ពុជានៅក្នុងតុលាការនេះ បានប៉ះពាល់ដល់បុគ្គលិកជាតិគ្រប់រូប និងប៉ះពាល់ដល់រឿងក្តីដែលមិនទាន់យកមកជំនុំជម្រះទាំងអស់។ ឥឡូវនេះ ភាពអសមត្ថភាពរបស់មន្ត្រីកម្ពុជានៅ អវតក ក្នុងការអនុវត្តប្រកបដោយឯករាជ្យ និងប្រកបដោយវិជ្ជាជីវៈ គឺមិនអាចប្រកែកបានឡើយ។ ដូច្នេះ សំណួរដែលមានអត្ថន័យតែមួយគត់ដែលនៅបើកចំហរចំពោះតុលាការនេះ គឺជាសំណួរដែលបានចោទសួរក្នុងតុលាការកាលពីថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០១២។ សំណួរនោះគឺ តើចៅក្រមអន្តរជាតិក្នុងអង្គជំនុំជម្រះនេះ ពោលគឺចៅក្រម Silvia Cartwright និង Jean-Marc Lavergne ជឿជាក់ដោយស្មោះត្រង់ថាសហសេវិកដែលជាចៅក្រមកម្ពុជារបស់គាត់អាចគាំទ្រសេចក្តីសម្រេចដែលផ្ទុយពីការសម្រេចដ៏អកុសល តែមិនអាចប្រកែកបានរបស់រដ្ឋាភិបាលដែរឬទេ[78]? ដូចដែល កសព បានលើកឡើង[79] មេធាវីការពារក្តី យល់ឃើញថាការឆ្លើយជា

---

[76] *ដូចជើងទំព័រខាងលើ*។

[77] កំណត់សម្គាល់ ដោយបើពិនិត្យមើលការពិតដែលថាគោលជំហរដែលមាននៅក្នុងសំណើសុំផ្អាកកិច្ចដំណើការនីតិវិធីនៅតែបន្តយកមកអនុវត្ត ចំពេលដែលមានកំណត់សម្គាល់សុំលាលែងពីតំណែងរបស់សហចៅក្រមបម្រុងអន្តរជាតិ និងដោយសារការពិតដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានដោះស្រាយក្តីកង្វល់នានាដែលបានលើកឡើងកាលពីមុន(សូមមើលឯកសារ **E-131/2/1** ) មេធាវីការពារក្តីសូមលើកឡើងសារជាថ្មីនូវទឡ្ហីករណ៍បែបនេះជាច្រើននៅក្នុងសំណើនេះ។

[78] សូមមើលឯកសារលេខ **E-1/53.1**, ប្រតិចារិក នៃដំណើការនីតិវិធីនៅក្នុងអង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១២ (ថ្ងៃសវនាការ៤១), ERN 00795037–00795152, pp 60:20–65:21, (សេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយមេធាវី Michel Pestman)។

[79] សូមមើលដូចខាងលើ, pp 65:24–67:5 (សេចក្តីសន្និដ្ឋានដែលធ្វើឡើងដោយមេធាវីតំណាងព្រះរាជអាជ្ញាអន្តរជាតិ William Smith )។

វិជ្ជមានទៅនឹងសំណួរបែបនេះ នឹងក្លាយជាភាពឆោតល្ងង់ ងងឹតងងុលដោយចេតនា ឬអាចធ្ងន់ធ្ងរជាងទៀតផងក៏ថាបាន។

២០. ជាថ្មីម្តងទៀត ស្ថានភាពគឺវាច្បាស់ណាស់។ ដោយប្រយ័ត្នប្រយែងក្នុងការរិះគន់របស់ខ្លួន អ្នកសង្កេតការមិនលម្អៀងនៃតុលាការនេះ បានឈប់បញ្ចេញមតិក្នុងភាពតានតឹងដែលមានលក្ខខណ្ឌ ។ អ្វីដែលត្រូវបានគេធ្លាប់ពិពណ៌នាជាច្រើនឆ្នាំថាជាលទ្ធភាពដែលបង្ករបញ្ហា ការភ័យខ្លាច ការព្រួយបារម្ភ និងការរំជើបរំជួលនោះ ឥឡូវបានក្លាយជាទៅជាការពិតហើយ[80] ។ ការជ្រៀតជ្រែកពីរាជរដ្ឋាភិបាលកម្ពុជានៅ អវតក គឺជាការពិតមិនអាចប្រកែកបានឡើយ។ បើពិចារណាទៅលើរបាយការណ៍អន្តរជាតិរបស់អ្នកប្រវត្តិវិទូដ៏គួរឱ្យគោរព [ការលាលែងពីតំណែងរបស់សហចៅក្រមអន្តរជាតិពីររូប] [គោលជំហរទន់ជ្រាយរបស់អង្គការសហប្រជាជាតិ] ឧបាយកលទុកច្ចរិតបន្ថែមទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា: ការពិតទាំងនេះមិនអាចរលាយសាបសូន្យបានឡើយ ។ និយាយដោយសាមញ្ញទៅ តុលាការនេះមិនឯករាជ្យពីអំណាចនីតិប្បតិបត្តិ(ដ៏ខ្លាំងខ្លា) របស់រាជរដ្ឋាភិបាលម្ពុជាទេ ហើយក៏គ្មានពេលណាមួយដែលតុលាការនេះធ្លាប់ឯករាជ្យពីអំណាចនេះដែរ។ ប្រសិនបើបុគ្គលម្នាក់ដែលមានការថ្លឹងថ្លែងគ្រប់គ្រាន់នៅតែមានមន្ទិលសង្ស័យលើបញ្ហានេះទៀត បុគ្គលនោះចាំបាច់ត្រូវតែទៅពិគ្រោះយោបល់ជាមួយគណៈរដ្ឋមន្ត្រី: "រដ្ឋាភិបាលមិនចង់បានការបរាជ័យឡើយ ដូច្នេះហើយខ្លួនអនុញ្ញាតឱ្យមានតែសំណុំរឿង ០០២ តែប៉ុណ្ណោះ"។

២១. តាមកាតព្វកិច្ចក្រមសីលធម៌ ចៅក្រម Silvia Cartwright និងចៅក្រម Jean-Marc Lavergne គួរតែទទួលស្គាល់ និងថ្កោលទោសជាសាធារណៈនូវកំហុសឆ្គងយ៉ាងធ្ងន់ធ្ងរដែលបានលាតត្រដាងចុងក្រោយក្នុងកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិចំពោះប្រព័ន្ធតុលាការដែលពួកគេបានធ្វើឱ្យទៅជាស្របច្បាប់ក្នុងកម្រិតណាមួយនោះតាមរយៈដំណោះស្រាយដ៏ស្ងប់ស្ងាត់របស់ពួកគេចំពោះបញ្ហាដ៏ចម្រូងចម្រាសបំផុតនៅ អវតក។ ការបន្តនៅស្ងៀមចំពោះចៅក្រមដែលបានបង្ហាញពីភក្តីភាពដ៏ច្បាស់ក្រឡែតរបស់ពួកគេ ចំពោះរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជានឹងក្លាយជាការថ្លង់ស្តាប់លែងឮសម្លេងអ្វីទាំងអស់ទៅវិញទេ។

## ខ. ចំណាត់ការស្របតាមវិធាន៣៥ ត្រូវបានអនុញ្ញាត និង តម្រូវឱ្យមានដើម្បីកំណត់ពីទំហំនៃការប៉ះពាល់ដល់សំណុំរឿង ០០២

[80] សំណើសុំផ្អាកការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តី កថាខណ្ឌ១២ (ការដកស្រង់ផ្នែកក្នុងត្រូវបានលុបចោល)។

២២. ដោយគ្មានមន្ទិលសង្ស័យ អង្គជំនុំជម្រះសាលាដំបូងអាចចាត់វិធានការណ៍ស្របតាមវិធាន៣៥[81]។ ជាងនេះទៅទៀត បើពិនិត្យមើលទៅលើការវិវត្តន៍ផ្នែកអង្គហេតុនាពេលចុងក្រោយនេះ[82] វាគួរតែធ្វើដូច្នេះដើម្បីការពារសុចរិតភាពនៃដំណើរការនីតិវិធីទាំងនេះ។ ដូចដែលបានវែកញែកកាលពីលើកមុនរួចហើយថា៖ "គ្មានការសម្រេចចិត្តសំខាន់ណាមួយរបស់តុលាការនេះអាចត្រូវបានចាត់ទុកជាសេចក្ដីសម្រេចស្របច្បាប់ទេ[83] លុះត្រាតែ ឬទល់តែ "បរិយាកាសដែលមានជាតិពុល" ដែលបណ្ដាលមកពីការជ្រៀតជ្រែកខាងនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នៅជុំវិញអាគារអវតក ទាំងមូលត្រូវបានបោសសម្អាត"។

២៣. ខណៈពេលដែលមេធាវីការពារក្ដីបានទទួលយកភាពគ្មានប្រយោជន៍នៃការអំពាវនាវរបស់ខ្លួនដល់ចៅក្រមកម្ពុជា ចុងក្រោយចៅក្រមអន្តរជាតិគួរតែដោះស្រាយ(ដើម្បីទុកជាកំណត់ត្រា)ទង្វើករណ៍ខាងក្រោមនេះដែលមកទល់ពេលនេះត្រូវបានអង្គជំនុំជម្រះសាលាដំបូង ទាំងមូលមើលរំលង៖

ក. "ទាក់ទងនឹងសំណុំរឿង០០២ ព្យសនកម្មបានធ្វើឡើងរួចហើយ។ សាក្សីសំខាន់មិនត្រូវបានកោះហៅឲ្យមកផ្ដល់សក្ខីកម្ម ហើយក៏គ្មានហេតុផលណាដែលរំពឹងថាពួកគេនឹងត្រូវបានកោះហៅឲ្យមកផ្ដល់សក្ខីកម្មដែរ ។ មិនតែប៉ុណ្ណោះ [ការចាកចេញរបស់សហចៅក្រមអន្តរជាតិពីររូប] ត្រូវតែបានគេមើលឃើញថាជាការបោះឆ្នោតមិនផ្ដល់ទំនុកចិត្តលើចៅក្រម យូ ប៊ុនឡេង ដែលជាបុគ្គលម្នាក់ទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការរៀបចំកិច្ចការស៊ើបសួរក្នុងសំណុំរឿង០០២។ បញ្ហាដែលចម្រូងចម្រាសបំផុតនោះគឺប្រហែលជាការលាតត្រដាងឲ្យដឹងនៅពេលថ្មីៗនេះដែលថាគ្រប់ការិយាល័យដែលទទួលខុសត្រូវក្នុងការស៊ើបអង្កេតជាប់ពាក់នឹងឥរិយាបទមួយដែលមិនហៅថាកំហុសព្រហ្មទណ្ឌនោះទេ ប៉ុន្តែជាការប្រព្រឹត្តខុស។ ដូច្នេះ សុចរិតភាពនៃសំណុំរឿង០០២ដែលជាមូលដ្ឋាននៃការជំនុំជម្រះនៅពេលខាងមុខ គឺមានលក្ខណៈគួរឲ្យសង្ស័យខ្លាំងណាស់។ គ្មានអ្វីមួយត្រឹមត្រូវអាចលេចចេញពីកិច្ចការមូលដ្ឋានដែលមិនស្ថិតស្ថេរនេះទេ[84]"។

---

[81] សូមមើលកថាខណ្ឌ១៦, ដូចដើងទំព័រខាងលើ។

[82] សូមមើលកថាខណ្ឌ៥ ដល់១៥, ដូចខាងលើ។

[83] សំណើសុំផ្អាកសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្ដី, កថាខណ្ឌ១ (ដកស្រង់សំដីរបស់លោក Steve Heder អតីតអ្នកវិភាគរបស់ កសចស)។

[84] សំណើសុំផ្អាកការថ្លែងបើក និងសវនាការលើអង្គសេចក្ដី, កថាខណ្ឌ១៣។

ខ. ទស្សនៈផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាលើសំណុំរឿង០០២ ត្រូវបានកំណត់ទុកជាមុន ។ ដូចដែលលោក ផៃ ស៊ីផាន បានគូសបញ្ជាក់ថា: "ការបរាជ័យនឹងមិនត្រូវបានអត់អោនឡើយ។ ជាក់ស្តែង ប្រភេទនៃជ័យជំនះដែលរដ្ឋាភិបាលបានគិត គឺអាច ឲ្យគេមើលឃើញបាន: *ការផ្តន្ទាទោស នួន ជា និងសហជនជាប់ចោទរបស់ គាត់*។ អ្វីដែលជាបញ្ហា ឬអ្វីគួរតែជាបញ្ហាចំពោះចៅក្រមនៅអង្គជំនុំជម្រះនេះ គឺថានៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបញ្ចេញយោបល់លើបញ្ហាជាក់លាក់ណាមួយ នៅក្នុងប្រទេសនេះមានរឿងពីរដែលច្បាស់លាស់ : (i)ការទទួលយកគោលជំហររបស់រដ្ឋាភិបាលកម្ពុជា គឺមានភាពច្បាស់ណាស់ចំពោះមន្ត្រី និងភ្នាក់ងារដែលគេរំពឹងថានឹងធានាការអនុវត្តន៍គោលជំហរនោះ និង (ii)លទ្ធផលដែលគេគិតទុកមុនច្បាស់ជានឹងកើតឡើង ។ ដូចដែលបានកត់សម្គាល់ [...] ក៏ដូចជាការទប់ទល់យ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលចំពោះការកាត់ទោសបន្ថែមទៀតដែរ ជាលទ្ធផលការគាំដោយចំហររបស់រាជរដ្ឋាភិបាលកម្ពុជាលើករណី០០២ គឺជាការប្រកាសឲ្យរៀបចំចំណាត់ការតាមផ្លូវតុលាការ[85]"។ ក្នុងបរិបទនេះ ការថ្លែងជាសាធារណៈរបស់លោកនាយករដ្ឋមន្ត្រី បានជម្រុញឲសាធារណៈរបស់លោកនាយករដ្ឋមន្ត្រី "បានធ្វើបុរេវិនិច្ឆ័យលើការវាយតម្លៃលើអង្គហេតុដោយ [ចៅក្រមជាតិ]"[86]។ ដោយចេញនូវអ្វីដែលគេយល់ឃើញថា ជាការណែនាំយ៉ាងច្បាស់ក្រឡែតចំពោះពាក្យសំដីរបស់គាត់ដែលថា នួន ជា *គឺជាឃាតករនិងជាជនដែលល់នៃអំពើប្រល័យពូជសាសន៍*[87] លោក ហ៊ុន សែន ជាលទ្ធផល បានចេញនូវសាលក្រមមួយក្នុងករណី០០២ ដែលសមាជិកចៅក្រមក្នុងអង្គជំនុំជម្រះសាលាដំបូងនឹងមិនហ៊ានរំលោភបំពាន។

គ. បើពិនិត្យទៅលើការខ្វះចំណាត់ការជួសជុលចាប់បាច់ យើងទាំងអស់គ្នាកំពុងធ្វើការក្នុងស្ថាប័នមួយដែលពេលនេះមានគុណវិបត្តិយ៉ាងពិតប្រាកដ។ សំណុំរឿង ០០២ ស្ថិតក្នុងស្ថានភាពយ៉ាប់យឺនដោយមិនទាន់បញ្ចប់នៅឡើយ។ ដូចដែលបានសង្កេតឃើញពីមុនខណៈដែលមេធាវីការពារក្តី នឹង (និងត្រូវតែ)បន្តបំពេញតួនាទីដើម្បីជាប្រយោជន៍ដល់កូនក្តីរបស់ខ្លួនតទៅទៀត គ្មានភាគីណាមួយត្រូវបានគេបង្ខំឲ្យចាប់ផ្តើមសវនាការ

---

[85] ដូចខាងលើកថាខណ្ឌទី១៤។

[86] សំណើសុំឲ្យមានចំណាត់ការសង្ខេបប្រឆាំងលោក ហ៊ុន សែន, កថាខណ្ឌទី១៣ (ការដកស្រង់ផ្នែកក្នុងត្រូវបានលុបចោល)។

[87] ដូចខាងលើកថាខណ្ឌទី៥។

ក្រោមលក្ខខណ្ឌថា ជារៀងរាល់ថ្ងៃអង្គការសហប្រជាជាតិ និងចៅក្រមអន្តរជាតិខក ខានមិនបានបំពេញតួនាទីរបស់ខ្លួន ដែលជាការឃ្លាតចេញឆ្ងាយទៅៗពីឧត្តមគតិដែល គេបានចាត់តាំង អវតក ឲ្យលើកតម្កើងនោះឡើយ[88]"។

វាជាការសន្និដ្ឋានទុកជាមុនមួយដ៏ច្បាស់លាស់ដែលថាអង្គជំនុំជម្រះសាលាដំបូង *ទាំងមូល* នឹងមិន ដោះស្រាយអង្គសេចក្តីសំខាន់នៃទឡ្ហីករណ៍ទាំងនេះឡើយ។ ជាអកុសល នេះគឺជាការសន្និដ្ឋានមួយ ដែលមិនអាចជៀសផុត ដែលបានទាញចេញពីកំណត់សម្គាល់: មន្ត្រីកម្ពុជានឹងមិនជំទាស់ទៅនឹង គោលជំហរជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជាបានឡើយ។ ជាការពិតណាស់ជាងនេះទៅទៀត ទស្សនៈ ដែលបានលើកឡើងរួចមកហើយរបស់រដ្ឋាភិបាលកម្ពុជាលើការជ្រៀតជ្រែកខាងនយោ បាយនៅក្នុងតុលាការនេះ គឺជាទស្សនៈមិនស្មោះត្រង់ដូចដែលគេបានរៀបរាប់ពីខាងលើ[89]។ ទោះ បីជាយ៉ាងណាក៏ដោយនៅក្នុងស្ថាប័ននេះមានបុគ្គលពីររូបដែលអាចដោះស្រាយជាសាធារណៈនូវ បញ្ហាដ៏លំបាកដែលមេធាវីការពារក្តីបានលើកឡើង។ ទាំងចៅក្រម Cartwright និងចៅក្រម Lavergne មានអំណាចផ្លូវច្បាប់និងកតាព្វកិច្ចខាងក្រមសីលធម៌ក្នុងការធ្វើចំណាត់ការ។

២៤. វានឹងមិនមែនជារឿងត្រឹមត្រូវទេក្នុងការបន្តលាក់បាំងនៅពីក្រោយការប្រឌិតដែលថាមានតែករណី ០០៣ និង០០៤ ប៉ុណ្ណោះ ដែលទទួលរងការជ្រៀតជ្រែកពីរាជរដ្ឋាភិបាលកម្ពុជា។ នៅពេលដែល សញ្ញានៃការជ្រៀតជ្រែកពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា (ដោយបើកចំហនៅគ្រប់ដំណាក់កាលនៃ ដំណើរការ) បានលេចចេញយ៉ាងច្បាស់ក្រឡែតនោះ ទង្វើដែលគ្មានការអៀនខ្មាស់បែបនេះ មិនបាន បិទបាំងនូវវិធីសាស្ត្រដ៏ប៉ិនប្រសព្វដែលប្រើដោយបុគ្គលដដែលដើម្បីធានាឲ្យមានការផ្តន្ទាទោសក្នុង ករណី០០២ និងដើម្បីការពារមន្ត្រីរដ្ឋាភិបាលកម្ពុជាមិនឲ្យជួបនូវភាពអាម៉ាស់ និង/ឬការលាត ត្រដាងការពិតណាមួយដែលអាចកើតឡើងបាន។ ពិតណាស់ ភាពប៉ិនប្រសព្វបែបនេះទាមទារឲ្យ មានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវដូចដែលមានចែងក្នុងវិធាន៣៥ នៃវិធានផ្ទៃក្នុង ហើយវាក៏មាន ការបង្ហាញជាបឋម( *prima facie)* យ៉ាងច្បាស់ក្រឡែតផងដែរថាការជ្រៀតជ្រែកបែបនេះពិតជា បានកើតឡើងមែន។ ដោយសារតែមានការលាតត្រដាងនៅពេលថ្មីៗនេះ វាពិតជាមានការជាប់ពាក់ ព័ន្ធជាពិសេសដែលថាអស់រយៈពេលជាយូរមកហើយដែលចៅក្រម យូ ប៊ុនឡេង បានបដិសេធមិន ចុះហត្ថលេខាលើដីកាកោះហៅសាក្សី ដែលជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជាឲ្យមកផ្តល់

---

[88] សំណើសុំផ្អាកការថ្លែងបើក និងសវនាការលើអង្គសេចក្តី, ចាខណ្ឌទី៥។

[89] ដូចខាងលើ, សូមមើលកថាខណ្ឌទី១៥។

សក្ខីកម្ម ដូច្នេះមានន័យថា ចៅក្រមរូបនេះបានគាំទ្រគោលជំហរដែលបានលើកឡើងដោយរដ្ឋាភិបាលលើបញ្ហានេះ។

២៥. ភាពច្បាស់លាស់មួយទៀតគឺថា អង្គការសហប្រជាជាតិនឹងមិនធ្វើចំណាត់ការដើម្បីជួសជុសបញ្ហានេះ*ប្រកបដោយប្រសិទ្ធិភាព*ឡើយ[90]។ ពិតណាស់ស្ថាប័នមួយនេះជាប់ពាក់ព័ន្ធទៅនឹងការជ្រៀតជ្រែកខាងនយោបាយមួយប្រភេទរបស់ខ្លួនផងដែរ ដោយព្យាយាមធានាថាលក្ខណៈនៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាបានប៉ះពាល់ដល់សំណុំរឿង០០២នោះ នឹងមិនត្រូវបានលាតត្រដាងឬស៊ើបអង្កេតឡើយ[91]។ ដូចដែលបានលើកយកមកវែកញែកកាលពីមុន: "ក្នុងនាមជាអង្គការមួយដែលបានប្តេជ្ញាចិត្តតាមការទំពឹងទុកថានឹងធានាភាពយុត្តិធម៌ក្នុងប្រទេសកម្ពុជា អង្គការសហប្រជាជាតិបានបានទុកអ្នកបំពេញកិច្ចការចាំបាច់តែសាមញ្ញរបស់ខ្លួនចោលដោយគ្មានកន្លែងការពារខ្លួនទាល់តែសោះ។ វិធានការតូចៗដែលត្រូវបាន ធ្វើឡើងបង្ហាញឲ្យឃើញថាមិនគ្រប់គ្រាន់ទេ ។ អង្គការដែលគ្មានអំណាច ឬដែលសមគំនិតគ្នា ឬទាំងពីរ មិនអាចចាត់ទុកថាជាមេដឹកនាំប្រកបដោយប្រសិទ្ធិភាព ឬអាចជឿទុកចិត្តបានតទៅទៀតទេក្នុងការប្រឆាំងទៅនឹងនិទណ្ឌភាពនៅកម្ពុជា[92]"។

---

[90] សូមមើលសេចក្តីថ្លែងការណ៍ [ស្តីពី អវតក] ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិតាមរយៈអ្នកនាំពាក្យ, ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១២។

[91] សូមមើលកថាខណ្ឌទី១២ (គ)។

[92] សំណើសុំផ្អាកការថ្លែងបើក និងសវនាការលើអង្គសេចក្តី, កថាខណ្ឌទី១៦, សូមមើលផងដែរ Peter Maguire អង្គការសហប្រជាជាតិ គ្មានសិទ្ធិប្រកាន់ខ្ជាំងពេកចំពោះ "សាលាក្តីខ្មែរក្រហមដែលមិនដំណើការឡើយ" (អត្ថបទរិះគន់), កាសែត ឌឹ ឃែម បូឌា ដេលី ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១២ (ប៉ុន្តែវាយឺតពេលហើយសម្រាប់អង្គការសហប្រជាជាតិក្នុងការទាមទារមកវិញនូវភាពបរិសុទ្ធខាងនយោបាយរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាដោយសារតែអង្គការមួយនេះបានចូលខ្លួនក្នុងការរៀបចំឲ្យមាន "តុលាការកូនកាត់" មួយនេះ។ អង្គការសហប្រជាជាតិគួរតែចាត់វិធានការណ៍ជាក់ស្តែងប្រឆាំងនឹងការគំរាមកំហែងដ៏ធ្ងន់ធ្ងរទាំងនេះ និងដកខ្លួនចេញនៅពេលដែលការជំនុំជម្រះក្តីទី២បានបញ្ចប់ ហើយយកពាក្យថាតុលាការកូនកាត់ដែលជាគំរូនេះដាក់ចូលទៅក្នុងធុងសំរាមប្រវត្តិសាស្ត្រវិញជាជាងសម្តែងតែពីក្តីបារម្ភ ឬ ក្តីបារម្ភធ្ងន់ធ្ងរ ប៉ុន្តែមិនបានចាត់វិធានការណ៍អ្វីសោះនោះ)។ Mark McDonald "ផ្លូវបត់បែនទៅកាន់យុត្តិធម៌ក្នុងប្រទេសកម្ពុជា", *International Herald Tribune*, ចុះថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១២ (Nate Thayer, អ្នកសារព័ត៌មានដែលមានចំណេះដឹងជ្រៅជ្រះអំពីប្រទេសកម្ពុជា និងរបបខ្មែរក្រហម, ហើយក៏ជាអ្នកដែលរិះគន់យ៉ាងខ្លាំងចំពោះតុលាការនេះផងដែរដែលគាត់បានប្រាប់ខ្ញុំកាលពីថ្ងៃអង្គារ៍ថាតុលាការនេះ ជា"ការបោកបញ្ឆោត និងការចំអកឡកឡើយដ៏គ្រោះថ្នាក់ចំពោះនីតិរដ្ឋព្រោះតុលាការនេះបានបង្កើតនូវគំរូថ្មីមួយដែលមិនអាចទទួលយកបានដើម្បីធ្វើឲ្យស្របច្បាប់នូវការជំនុំជម្រះក្តីឆាកល្ខោនតាមបែប Stalinist នៅក្នុងសវតស្សទី២១"។ [...] លោក Thayer បានមានប្រសាសន៍ថា "ដំណើការតុលាការគឺស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់អតីតខ្មែរក្រហម"។ ដោយសំដៅដល់ [ចៅក្រម យូ ប៊ុនឡេង] លោក Thayer បាននិយាយថា "ចៅក្រមត្រូវបានគេទិញ និងចំណាយលុយឲ្យក្នុងលក្ខណៈតម្លាភាពដ៏គួរឲ្យសោចចំអកជាទីបំផុត វាជារឿងអាស្រូវមួយដែលអង្គការសហប្រជាជាតិបណ្តោយខ្លួនជាភាគីមួយនៃរឿងកប្លែងសើច

២៦. ដោយទទួលយកការពិតដែលអកុសលទាំងនេះ "វានឹងនៅសល់តែជម្រើសស្របច្បាប់ពីតែប៉ុណ្ណោះសម្រាប់ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសពោល គឺត្រូវចាកចេញ ឬដោះឱ្យរួចពីកាតព្វកិច្ច ដោយហេតុថាតុលាការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ គឺមិនអាចធ្វើបានទេនៅតុលាការនេះ។ អ្វីដែលអាចជាបញ្ហាប្រឈម គឺកាតព្វកិច្ចរបស់តុលាការនានានៅក្នុងសង្គមប្រជាធិបតេយ្យ តាមរយៈសកម្មភាពរបស់អ្នកច្បាប់របស់សង្គម ទាំងនោះដើម្បីញុំាងឱ្យមានការជឿទុកចិត្ត ទៅលើសាធារណៈជន និងសំខាន់ជាការជឿជាក់ លើជនជាប់ចោទ ដរាបណាមានការពាក់ព័ន្ធកិច្ចដំណើការនីតិវិធីព្រហ្មទណ្ឌ[93]"។

## គ.ស្ថានភាពនៅពេលបច្ចុប្បន្នតម្រូវឱ្យផ្អាកដំណើរការនីតិវិធី

២៧. "សេណារីយ៉ូដែលកំពុងប្រឈម អវតក នាពេលនេះ ចាត់ទុកជាការរំលោភធ្ងន់ធ្ងរលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការកាត់សេចក្តីនៅចំពោះតុលាការឯករាជ្យមួយ។ យោងតាមច្បាប់យុត្តិសាស្ត្រដែលបានរៀបរាប់ពីខាងលើការបំពានដែលមានលក្ខណៈ"ជាក់ស្តែង"នេះ នឹងបង្ហាញថា"វិធានការខ្លាំងបំផុត"ក្នុងការបដិសេធយុត្តាធិការ គឺជាការត្រឹមត្រូវ[94]"។ "អន្តរាយរបស់ចេតនាសុចរិតនៃភាពសុទិដ្ឋិនិយមផ្នែកតុលាការអាចជាបញ្ហាតិចតួច តែនៅពេលតំណាលគ្នានោះវាក៏អាចបង្កបញ្ហាធំដំបានដែរ។ កម្លាំងចលករនៃស្ថាប័ន- ដូចជាការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិចូលក្នុងរដ្ឋដែលប្រើអំណាចផ្តាច់ការ-មិនជំនះបានដោយភាពងាយស្រួលឡើយ។ រឿងជាច្រើនអាចនឹងមានផលអាក្រក់ខ្លាំងដូចជាការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ សុចរិតភាពរបស់តុលាការ"[95] និងប្រហែលជាសញ្ញាជោគជ័យនៃការបង្កើតនីតិរដ្ឋនៅថ្ងៃមួយនៅក្នុងប្រទេសកម្ពុជា។

## V. សេចក្តីសន្និដ្ឋាន

លេងនេះ។ រឿងតែមួយគត់ដែលអង្គការសហប្រជាជាតិ និងប្រទេសម្ចាស់ជំនួយអាចធ្វើបានដើម្បីឱ្យអ្នកដែលពឹងផ្អែកលើប្រព័ន្ធច្បាប់អន្តរជាតិមិនជំនឿចិត្តឡើងវិញ គឺត្រូវដកខ្លួនចេញនៅពេលឥឡូវនេះ"។ លោក Thayer បានឱ្យដឹងទៀតថា "ប្រសិនបើប្រជាជនកម្ពុជាចង់មានសវនាការឆាកកំប្លុកកំប្លែងតាមបែបនយោបាយ សូមទុកឱ្យពួកគេធ្វើវាដោយគ្មានការគាំទ្ររបស់អង្គការពិភពលោកមួយនេះ")។

[93] សំណើសុំផ្អាកការថ្លែងបើក និងសវនាការលើអង្គសេចក្តី, កថាខណ្ឌទី១៨, (ការដកស្រង់ផ្ទៃក្នុងត្រូវបានលុបចោល)។

[94] ដូចខាងលើ, សូមមើលកថាខណ្ឌទី១៧។

[95] បណ្តឹងសារទុក្ខ ទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌទី៣៩។

២៨. អាស្រ័យហេតុនេះ អនុលោមតាមវិធាន ៣៥ និងយុត្តិសាស្ត្រដោយបានរៀបរាប់ពីខាងលើ តទៅនេះមេធាវីការពារក្តីសូមស្នើសុំឲ្យមាន: (i) ការទទួលស្គាល់ពីផលប៉ះពាល់នៃកំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ (ii) ការស៊ើបអង្កេតពេញលេញទៅលើឥទ្ធិពលនៃការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលទៅលើភាពត្រឹមត្រូវនៃករណី០០២ និង (iii) ការផ្អាកកិច្ចដំណើរការនីតិវិធីរង់ចាំលទ្ធផលនៃការស៊ើបអង្កេតពេញលេញសិន ។ ដោយគិតថាអង្គជំនុំជម្រះនឹងធ្វើការបដិសេធ មេធាវីការពារក្តីសូមស្នើឲ្យចៅក្រម Cartwright និងចៅក្រម Lavergne ចេញទស្សនៈដាច់ដោយឡែក ដោយធ្វើការថ្កោលទោសចំពោះការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាល និងជំទាស់ទៅនឹងការខកខានរបស់សហសេវិករបស់ពួកគាត់ក្នុងការធ្វើចំណាត់ការ។

**សហមេធាវីការពារក្តីលោក នួន ជា**

Michiel PESTMAN　　Andrew IANUZZI　　Jasper PAUW